គម្រោងផ្តល់សេវាកម្មបរិស្ថាន
ប្រកបដោយចីរភាព

SPES
SUSTAINABLE PROVISION of ECOSYSTEM SERVICES

# សៀវភៅបណ្តុះបណ្តាលស្តីពី
# ការរៀបចំផែនការដោយមានការចូលរួម



រៀបចំដោយៈ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល
គាំទ្រថវិកាដោយៈ សហភាពអឺរ៉ុប តាមរយៈអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ

សហភាពអឺរ៉ុប

FAUNA & FLORA INTERNATIONAL

THE LEARNING INSTITUTE
People and Natural Resources

លេខ១
កក្កដា
២០១២

# មាតិកា


| | ទំព័រ |
|---|---|
| បុព្វកថា | i |
| ផ្នែកទី ១៖ ទស្សនៈទូទៅនៃការរៀបចំផែនការដោយមានការចូលរួម | ១ |
| ១.១ និយមន័យការចូលរួម | ១ |
| ១.២ កម្រិតនៃការចូលរួម | ២ |
| ១.៣ និយមន័យការរៀបចំផែនការ | ២ |
| ១.៤ និយមន័យការរៀបចំផែនការដោយមានការចូលរួម | ៣ |
| ១.៥ សារៈសំខាន់នៃការរៀបចំផែនការដោយមានការចូលរួម | ៤ |
| ១.៦ ការប្រមូលព័ត៌មានសម្រាប់ការរៀបចំផែនការ | ៥ |
| ១.៦.១ ប្រភេទព័ត៌មាន | ៥ |
| ១.៦.២ ការប្រមូលព័ត៌មាន | ៥ |
| ផ្នែកទី ២៖ វិធានសម្រាប់ការប្រមូលព័ត៌មានដើម្បីរៀបចំ ផែនការអភិវឌ្ឍន៍ និងកម្មវិនិយោគ ឃុំ/សង្កាត់ | ៨ |
| ២.១ គោលគំនិតទូទៅរបស់ការវាយតម្លៃជនបទដោយមានការចូលរួម | ៨ |
| ២.២ ឧបករណ៍សម្រាប់ការប្រមូលព័ត៌មានដោយមានការចូលរួម | ៩ |
| ២.២.១ ការអនុវត្តក្នុងការសួរដេញដោល | ១០ |
| ២.២.២ ការគូរផែនទីដោយមានការចូលរួម | ១០ |
| ២.២.៣ ប្រតិទិនរដូវកាល | ១៣ |
| ២.២.៤ ការវិភាគអ្នកពាក់ព័ន្ធ | ១៦ |
| ២.២.៥ ចំណាត់ថ្នាក់បញ្ហា | ១៧ |
| ២.២.៦ ការវិភាគដើមឈើបញ្ហា | ១៩ |
| ២.២.៧ ការស្វែងយល់ពីទស្សនវិស័យ | ២១ |
| ២.២.៨ ការវិភាគពីតម្រូវការ | ២២ |
| ២.២.៩ វិភាគឧបសគ្គ និងដំណោះស្រាយ | ២៣ |
| ផ្នែកទី៣៖ នីតិវិធីនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | ២៦ |
| ៣.១ ការត្រៀមរៀបចំ | ២៧ |
| ៣.២ ការប្រមូលព័ត៌មាន | ៣៣ |
| ៣.៣ ការវិភាគព័ត៌មាន | ៣៤ |
| ៣.៤ ការប្រើប្រាស់សេចក្តីសន្និដ្ឋាន | ៣៥ |
| ការពន្យល់ពាក្យគន្លឹះ | ៣៧ |
| ឯកសារយោង | ៤១ |

# បុព្វកថា

គម្រោងផ្តល់សេវាកម្មបរិស្ថានប្រកបដោយចីរភាព[1] គឺជាគម្រោងដែលទទួលបានការគាំទ្រ មូលនិធិពីសំណាក់សហភាពអឺរ៉ុប (EU) តាមរយៈអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ (FFI) ដើម្បីអនុវត្ត សាកល្បងនៅក្នុងខេត្តពោធិ៍សាត់ និងកោះកុង។ វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល (The Learning Institute) គឺជាដៃគូសហការសម្រាប់ការអនុវត្តគម្រោងនេះ ក្នុងផ្នែកបង្កើនការយល់ដឹងអំពី ការផ្តល់នូវនិរន្តរភាពសេវាកម្មបរិស្ថាន នៅតំបន់ជួរភ្នំក្រវាញទៅដល់បណ្តាអ្នកពាក់ព័ន្ធ ជាពិសេសអាជ្ញាធរ និងសហគមន៍មូលដ្ឋាន។ នៅចុងឆ្នាំ២០១១ និងដើមឆ្នាំ ២០១២ ក្រុមការងារគម្រោងការផ្តល់នូវសេវាកម្ម បរិស្ថានប្រកបដោយនិរន្តរភាពរបស់វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលបានរៀបចំឲ្យមាននូវសិក្ខាសាលាស្តីពី ការប៉ានប្រមាណតម្រូវការវគ្គបណ្តុះបណ្តាលឡើងនៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ និងស្រុកថ្មបាំង ខេត្តកោះកុង។ បន្ទាប់ពីការផ្ទៀងផ្ទាត់លទ្ធផលពីសំណាក់បណ្តាអ្នកពាក់ព័ន្ធរួចមក ក្រុមការងារគម្រោងបានរកឃើញនូវតម្រូវការជាអាទិភាពដើម្បីរៀបចំជាវគ្គបណ្តុះបណ្តាលចំនួនបួន។ តម្រូវការទាំងនោះរួមមាន៖ ១- ការគ្រប់គ្រងធនធានធម្មជាតិ ២- ការប្រាស្រ័យទាក់ទង ការកសាងបណ្តាញ និងភាពជាដៃគូ ៣- ភាពជាអ្នកដឹកនាំ និងការរៀបចំសហគមន៍ និង ៤- ការកសាងផែនការដោយមានការចូលរួម។ លទ្ធផលទាំងនេះបានត្រូវលើកយកទៅដើម្បីចងក្រងជាមេរៀន និងសម្ភារសម្រាប់បណ្តុះបណ្តាលកសាងសមត្ថភាព និង ចំណេះដឹងទៅដល់ក្រុមគោលដៅគម្រោង ដែលក្នុងនោះរួមមានអាជ្ញាធរភូមិឃុំ ក្រុមសមាជិកគណៈកម្មការ និងប្រជាពលរដ្ឋដែលមកពីតំបន់គោលដៅនៅក្នុងខេត្តពោធិ៍សាត់ និងកោះកុង។

ដោយឡែក សៀវភៅមេរៀនស្តីពី ការកសាងផែនការដោយមានការចូលរួម នេះនឹងមានសារៈប្រយោជន៍សម្រាប់ជាជំនួយដល់អ្នករៀនសូត្រដើម្បីស្វែងយល់ពីមូលដ្ឋានគ្រឹះ និងទស្សនៈទាននៃការកសាងផែនការដោយមានប្រសិទ្ធិភាព ហើយក៏ដើម្បីបង្កើនសមត្ថភាពបន្ថែមទៀតទៅលើចំណេះដឹង និងបទពិសោធន៍ដែលកំពុងតែអនុវត្តជាក់ស្តែង នៅក្នុងសហគមន៍របស់ខ្លួន។ លើសពីនេះទៅទៀត គឺដើម្បីចែករំលែកចំណេះដឹងលើបច្ចេកទេសមួយចំនួនទាក់ទងនឹងការកសាងផែនការដោយមានការចូលរួម តាមរយៈការឆ្លុះបញ្ចាំងទៅលើការអនុវត្តការងារបច្ចុប្បន្នរបស់ពួកគាត់ជាមួយនឹងអ្វីដែលក្រុមអ្នកសម្របសម្រួលរបស់វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលបានចែករំលែកក្នុងវគ្គបណ្តុះបណ្តាលផ្ទាល់។

ក្រុមការងារនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល សង្ឃឹមនិងជឿជាក់យ៉ាងមុតមាំថាអ្នកអនុវត្តការងារពាក់ព័ន្ធទាំងអស់រួមមានស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិល ក៏ដូចជាសហគមន៍មូលដ្ឋាននឹងប្រើប្រាស់សៀវភៅមេរៀននេះជាប្រយោជន៍រួមដើម្បីគាំទ្ររាល់ការអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួន បូករួមជាមួយនឹងបទពិសោធន៍ការងារជាក់ស្តែងនៅមូលដ្ឋានរៀងៗខ្លួន ក៏ដូចជាបន្តការចែករំលែកឲ្យបានទូលំទូលាយផងដែរ។

ក្រុមការងារនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល យើងខ្ញុំនៅតែមានជំនឿថា សៀវភៅបណ្តុះបណ្តាលនេះនឹងនៅតែមានចន្លោះខ្វះខាតជាក់ជាពុំខាន ហើយយើងខ្ញុំក៏សង្ឃឹមផងដែរថាអស់លោក លោកស្រីដែលជាអ្នកប្រើប្រាស់ទាំងអស់នឹងជួយផ្តល់មតិយោបល់ល្អៗ ដែលបានពីការប្រើប្រាស់ផ្ទាល់ប្រយោជន៍ដើម្បីជួយកែលម្អរឱ្យសៀវភៅនេះកាន់តែមានភាពសុក្រឹត និងភាពប្រសើរឡើងសម្រាប់ការបោះពុម្ពលើកក្រោយៗទៀត។

**សូមអរគុណ**

[1] Sustainable Provision of Ecosystem Services (SPES)

# ផ្នែកទី១៖ ទស្សនៈទូទៅនៃការរៀបចំផែនការដោយមានការចូលរួម

## ១.១ និយមន័យការចូលរួម

- គឺជាការពាក់ព័ន្ធដោយផ្ទាល់ និងយ៉ាងសកម្មពីសំណាក់ប្រជាជននៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ពួកគេ។
- គឺជាដំណើរការដែលប្រជាជនមានលទ្ធភាពរៀបចំ ហើយអាចកំណត់នូវតម្រូវការរបស់ពួកគេ ចែករំលែកការច្នៃប្រឌិត បទពិសោធន៍ ការអនុវត្ត និងវាយតម្លៃនូវសកម្មភាពជាក់លាក់ណាមួយ តាមរយៈគំនិតផ្តួចផ្តើមផ្ទាល់របស់ពួកគេ។
- ជាការចូលរួមរបស់ក្រុមអ្នកទទួលផលក្នុងការសម្រេចនូវសមិទ្ធិផលនានា ពោលគឺមិនមែនធ្វើជំនួសប្រជាជននោះទេ។



❖ **ការចូលរួមមានសារៈសំខាន់ពីព្រោះ ៖**

- ធ្វើឱ្យមនុស្សទទួលបានចំណេះដឹង ទស្សនៈ ជំនាញផ្សេងៗគ្នា និងស្វែងយល់ពីធនធានដែលត្រូវប្រើប្រាស់ឱ្យកាន់តែមានប្រសិទ្ធភាព។
- គំនិតផ្តួចផ្តើមត្រូវបានយកទៅអនុវត្តយ៉ាងមានប្រសិទ្ធភាព ទទួលផលល្អ និងកាន់តែមាននិរន្តរភាព។
- ធ្វើឱ្យមនុស្សចេះចែករំលែក និងធ្វើឱ្យពួកគេមានគំនិតទូលំទូលាយទៅលើបញ្ហាធនធាននានា និងឱកាសផ្សេងៗ។
- ធ្វើឱ្យមនុស្សចេះចែករំលែក និងបង្ហាញពីភាពផ្សេងគ្នារបស់ពួកគេទៅលើចំណេះដឹង និងជំនាញដែលពាក់ព័ន្ធ។
- ធ្វើឱ្យមានការអភិវឌ្ឍ តាមរយៈការផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងលក្ខណៈប្រជាធិបតេយ្យ និងស្មើភាព។

## ១.២ កម្រិតនៃការចូលរួម

ការចូលរួមមានច្រើនកម្រិតផ្សេងៗគ្នាផ្អែកទៅតាមស្ថានភាព ឬកាលៈទេសៈខុសៗគ្នា។ ចំណុចសំខាន់អ្នកត្រូវសម្រេចចិត្តថាតើអ្នកកំពុងស្ថិតក្នុងស្ថានភាពបែបណា។ មិនមែនមានតែ "សហគមន៍" តែមួយប៉ុណ្ណោះទេ ប៉ុន្តែមានអ្នកពាក់ព័ន្ធច្រើនណាស់ ដូច្នេះហើយទើបការធ្វើឱ្យមានការចូលរួមទាមទារពេលវេលាយូរ។ ការចូលរួមត្រូវបានកំណត់ថាមានប្រាំកម្រិតសម្រាប់ការរៀបចំធ្វើផែនការ គឺៈ

- **ការផ្តល់ព័ត៌មាន**

សំដៅទៅលើ ការផ្តល់ព័ត៌មានដល់ប្រជាជនចំពោះអ្វីដែលបានកំណត់ចូលទៅក្នុងផែនការ។

- **ការពិគ្រោះយោបល់**

សំដៅទៅលើបញ្ហាត្រូវរកឱ្យឃើញ និងកំណត់បញ្ហាទាំងនោះ ហើយជម្រើសជាច្រើនត្រូវបានដាក់ចេញដល់ប្រជាជនដើម្បីទទួលនូវយោបល់ត្រលប់មកវិញ។

- **ការសម្រេចចិត្តរួមគ្នា**

សំដៅទៅលើ ការលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីផ្តល់នូវគំនិតបន្ថែមរួមជាមួយនឹងជម្រើសផ្សេងៗ មុននឹងពួកគេទាំងអស់គ្នាធ្វើការសម្រេចចិត្តរួមគ្នាដើម្បីជ្រើសរើសផ្លូវដ៏ល្អប្រសើរបំផុតសម្រាប់អនុវត្ត។

- **ការធ្វើសកម្មភាពជាមួយគ្នា**

សំដៅទៅលើ ការរៀបចំបង្កើតក្រុមការងារជាដៃគូរដើម្បីទទួលខុសត្រូវធ្វើលើការងារនោះ។

- **ការគាំទ្រ**

ការគាំទ្រដោយសេរីលើគម្រោងដែលមានការចូលរួមពីសហគមន៍មានន័យថា គឺជាការជួយរាល់សកម្មភាពអភិវឌ្ឍន៍ និងអនុវត្តផែនការរបស់ពួកគេ។ អ្នកគ្រប់គ្រងធនធាន គឺជាអ្នកដែលជំរុញ និងកំណត់កម្រិតនៃការគាំទ្រ។

## ១.៣ និយមន័យការរៀបចំផែនការ

ការរៀបចំផែនការ ត្រូវបានកំណត់ន័យផ្សេងៗគ្នាទៅតាមទស្សនៈ និងការយល់ឃើញរបស់បុគ្គល ឬស្ថាប័នរៀងៗខ្លួន។ ខាងក្រោមនេះជានិយមន័យមួយចំនួនសម្រាប់ធ្វើការពិចារណាៈ

- ការរៀបចំផែនការ គឺជាដំណើរការនៃការកំណត់គោលដៅ រៀបចំយុទ្ធសាស្ត្រ ការគ្រោងការងារនិងតារាងពេលវេលាដើម្បីសម្រេចគោលដៅ។
- ការរៀបចំផែនការ គឺជាផ្នែកមួយយ៉ាងសំខាន់នៃការគ្រប់គ្រងគម្រោង និងជារបៀបនៃការគ្រប់គ្រងពេលវេលា ហើយវាគឺជាការរៀបចំបណ្តុំនៃសកម្មភាពតាមជំហាននីមួយៗ ដើម្បីសម្រេចគោលដៅជាក់លាក់មួយចំនួន។
- ការរៀបចំផែនការ គឺជាប្រព័ន្ធនៃការរៀបចំដំណើរការសម្រាប់ថ្ងៃអនាគតដោយកំណត់គោលដៅជ្រើស-រើសយុទ្ធសាស្ត្រ ជ្រើសរើសសកម្មភាពរៀបចំតារាងពេលវេលា ឬធនធានថវិកាសម្រាប់កំឡុងពេលណាមួយ។
- យើងអាចកំណត់ន័យជាទូទៅមួយថា ការរៀបចំផែនការគឺជាដំណើរការនៃការរៀបចំបណ្តុំសកម្មភាពនានា ផ្អែកទៅតាមពេលវេលា យុទ្ធសាស្ត្រ ឬធនធានដែលបានកំណត់ និងផ្អែកទៅតាមជំហាននីមួយៗ ដែលបានគ្រោងទុកដើម្បីសម្រេចឱ្យបានដល់គោលដៅរបស់ឃុំ ឬសហគមន៍មូលដ្ឋាន។



❖ **សារៈសំខាន់នៃការរៀបចំផែនការៈ**

ផែនការ គឺជាផ្នែកដ៏សំខាន់មួយនៃគ្រប់ការងារដែលយើងបម្រុងនឹងធ្វើ ប្រសិនបើគ្មានផែនការទេនោះ យើងនឹងមិនអាចបំពេញការងារចប់ដោយប្រសិទ្ធភាព ទទួលបានផលល្អ និងលក្ខណៈសន្សំសម្ចៃបានទេ។ ដូច្នេះ ការរៀបចំផែនការមានសារៈសំខាន់ណាស់សម្រាប់បុគ្គលម្នាក់ៗ ស្ថាប័នទោះ តូចក្តី ឬធំក្តី ។ ខាងក្រោមនេះ គឺជាសារៈសំខាន់មួយចំនួននៃការរៀបចំផែនការៈ

- ធ្វើឱ្យយើងយល់ច្បាស់ទៅលើអ្វីដែលយើង ក៏ដូចជាបុគ្គលិក ឬក្រុមអ្នកអនុវត្តចាំបាច់ត្រូវធ្វើដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍
- ធ្វើឱ្យក្រុមការងារ ឬសមាជិកអាចធ្វើការសម្រេចចិត្តរួមគ្នា សហការគ្នាទៅវិញទៅមក និងសម្រប-សម្រួលសកម្មភាពនានានៅក្នុងក្រុមមានភាពរលូន
- ធ្វើឱ្យយើងអាចកំណត់ទៅលើសកម្មភាពនានាដែលត្រូវអនុវត្ត និងប្រើប្រាស់ធនធានដែលមានស្រាប់
- ផ្តល់វិធីសាស្ត្រធ្វើឱ្យយើងមានភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយស្ថាប័នផ្សេងទៀត
- ផ្តល់នូវការណែនាំដ៏ស្និតស្នាលសម្រាប់ការអនុវត្តការងារពីមួយថ្ងៃទៅមួយថ្ងៃក្នុងស្ថាប័នរបស់យើង
- គាំទ្រដល់ការគ្រប់គ្រង និងអភិបាលកិច្ចនៃស្ថាប័ន
- បង្ហាញពីគោលដៅដើម្បីឱ្យយើងងាយស្រួលក្នុងការត្រួតពិនិត្យលើលទ្ធផលថាតើអាចទទួលជោគជ័យ ព្រមទាំងវាយតម្លៃលើផលប៉ះពាល់ដែលបានមកពីការអនុវត្ត
- កំណត់បាននូវអ្នកទទួលផល និងអ្នកទទួលខុសត្រូវ។

## ១.៤ និយមន័យការរៀបចំផែនការដោយមានការចូលរួម

ការរៀបចំផែនការដោយមានការចូលរួម គឺជាដំណើរការនៃការប្រមូលនូវការធ្វើសេចក្តីសម្រេចចិត្តរួមគ្នា ពីអ្នកចូលរួមនានាដើម្បីរៀបចំផែនការ។ ឧទាហរណ៍ដូចជាគម្រោងអភិវឌ្ឍន៍សហគមន៍ព្រៃឈើយើងត្រូវគិតថា តើត្រូវធ្វើសកម្មភាពអ្វីខ្លះ ធ្វើនៅពេលណា ដោយអ្នកណា ប្រើប្រាស់ធនធានយ៉ាងដូចម្តេច? និងត្រូវរៀបចំផែនការសកម្មភាពយ៉ាងណាដើម្បីធ្វើឱ្យសម្រេចបាននូវគោលបំណងជាក់លាក់។



## ១.៥ សារៈសំខាន់នៃការរៀបចំផែនការដោយមានការចូលរួម

មានហេតុផលមួយចំនួនដែលបង្ហាញឱ្យឃើញថា ការរៀបចំផែនការដោយមានការចូលរួមមានសារៈសំខាន់ដូចជា៖

- ❖ បង្កើនគុណភាពនៃអភិបាលកិច្ចមូលដ្ឋានតាមការបង្កើតឱ្យមានដំណើរការបែបប្រជាធិបតេយ្យ និងសមធម៌។ អ្នកក្រីក្រជាញឹកញាប់មានសម្លេងតែបន្តិចបន្តួចប៉ុណ្ណោះ ជាពិសេសនៅក្នុងការសម្រេចចិត្ត។ ការពិគ្រោះ យោបល់ និងសន្ទនារវាងអាជ្ញាធរមូលដ្ឋាន និងក្រុមដែលមានចំណាប់អារម្មណ៍តំណាងឱ្យអ្នកក្រីក្រអាចបង្កើននូវ ការយកចិត្តទុកដាក់ និងមានឥទ្ធិពលចំពោះការសម្រេចចិត្តទាំងនោះបាន។
- ❖ ជួយលើកទឹកចិត្តសហគមន៍មូលដ្ឋានឱ្យមានការពាក់ព័ន្ធ និងដឹងឮចំពោះតួនាទីរបស់ពួកគេនៅក្នុងអភិបាល កិច្ចមូលដ្ឋានព្រមទាំងធ្វើឱ្យពួកគេមានការទទួលខុសត្រូវកាន់តែខ្លាំងឡើងចំពោះតួនាទីទាំងនោះ។ ការអនុវត្តបែប នេះអាចជួយកាត់បន្ថយនូវជម្លោះ និងធ្វើឱ្យប្រជាជននៅថ្នាក់មូលដ្ឋានមានអារម្មណ៍ជាម្ចាស់ចំពោះផែនការទាំង នោះ។
- ❖ អាចផ្តល់លទ្ធផលយ៉ាងល្អប្រសើរនៅក្នុងកម្មវិធីនានា។ តាមរយៈការពិគ្រោះយោបល់ជាមួយអ្នកក្រីក្រយើងអាចស្គាល់ពីកង្វល់ និងតម្រូវការរបស់ពួកគេ។ ហើយជាលទ្ធផលនៃការពិគ្រោះយោបល់នេះយើងនឹងកំណត់ ពីសកម្មភាពមួយចំនួនដែលត្រូវយកទៅអនុវត្តឱ្យចំទៅនឹងអ្វីដែលសហគមន៍មូលដ្ឋានកំពុងតែប្រឈម។
- ❖ អាចបង្កើនឱ្យមានតម្លាភាពនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាល។ ការអនុវត្តបែបនេះធ្វើឱ្យប្រជាជនដឹងពីវិធី និងមូលហេតុមួយចំនួនដែលធ្វើឱ្យអាជ្ញាធរមូលដ្ឋានធ្វើសេចក្តីសម្រេចចិត្ត។ វាក៏ជារបៀប ដែលបង្ហាញឱ្យឃើញថាសមាជិកអាជ្ញាធរមូលដ្ឋានខ្លួនឯងត្រូវតែមានការទទួលខុសត្រូវខ្ពស់ចំពោះអ្វី ដែលពួកគេ បនាកំណត់នៅក្នុងផែនការ។ ការធ្វើបែបនេះ គឺអាចបង្កើននូវការយល់ដឹង និងជំនឿទុកចិត្តលើគ្នា ទៅវិញទៅមក រវាងសហគមន៍មូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន។

## ១.៦ ការប្រមូលព័ត៌មានសម្រាប់ការរៀបចំផែនការ

ការប្រមូលព័ត៌មាន គឺជាការរុករកពីអ្វីដែលកើតឡើងនឹងកំពុងតែកើតឡើងនៅក្នុងតំបន់ ឬសហគមន៍ណាមួយ។ ការប្រមូលព័ត៌មានគឺមានវិធីសាស្ត្រជាច្រើនក្នុងការរកឱ្យឃើញពីមូលហេតុពិត ការកំណត់ឱ្យបានច្បាស់ពីបញ្ហា និងតម្រូវការ ដើម្បីឱ្យការប្រមូលព័ត៌មានបានគ្រប់គ្រប់ជ្រុងជ្រោយ គឺកើតចេញពីការសួរគ្នាទៅវិញទៅមក ឬគេអាចហៅថាជាការសម្ភាសន៍គ្នា ព្រោះការសម្ភាសន៍ពេលខ្លះបានកើតឡើងដោយ មានការរៀបចំសំនួរជាមុន និងពេលខ្លះសួរសំនួរទៅតាមដំណើររឿងដោយមិនបានគ្រោងទុក ឬទៅតាមកាលវេលាដែលគេមើលឃើញ។ មុនពេលចាប់ផ្ដើមប្រមូលព័ត៌មានអ្វីដែលត្រូវធ្វើមុនគេ គឺធ្វើការប្រជុំគ្នាជាមួយក្រុមការងារដើម្បីរៀបចំផែនការសកម្មភាព ហើយនឹងបញ្ជាក់ពី គោលបំណង ការរំពឹងទុក សកម្មភាព វិធីសាស្ត្រប្រមូលព័ត៌មាន ការវិភាគ (ស្ថានភាពទូទៅ ព័ត៌មាន..) ជាមុនសិន។ ម៉្យាងវិញទៀតក្រុមការងារត្រូវតែយល់ពីវិធីសាស្ត្រសម្រាប់ប្រមូលព័ត៌មាន ហើយដើម្បីឱ្យការប្រមូលព័ត៌មានវាកាន់តែប្រសើរ យើងត្រូវមានទាក់ទងនឹងស្ថាប័នដែលមានបទពិសោធន៍ ដូចជាអង្គការមិនមែនរាជរដ្ឋាភិបាល និងរាជរដ្ឋាភិបាលដើម្បីជួយដល់ក្រុមការងារមុនពេលចុះអនុវត្តសកម្មភាព។

និយាយជារួមមក មុននឹងធ្វើការប្រមូលព័ត៌មានសមាជិកក្នុងក្រុមត្រូវពិចារណាលើគោលគំនិតសំខាន់ៗមួយចំនួនដូចជា តើប្រភេទព័ត៌មានអ្វីខ្លះដែលយើងត្រូវការ? តើការប្រមូលព័ត៌មានមាន ប៉ុន្មានប្រភេទ?

### ១.៦.១ ប្រភេទព័ត៌មាន

ចំពោះរាល់សកម្មភាពទាំងអស់ រួមមានការរៀបចំគម្រោងក្ដី ការរៀបចំផែនការក្ដី សុទ្ធតែទាមទារឱ្យបានការប្រមូលព័ត៌មានឱ្យបានច្បាស់លាស់។ បើពុំមានការប្រមូលពត៌មានច្បាស់លាស់ទេនោះការរៀបចំគម្រោង ឬផែនការរបស់យើងគឺស្ថិតនៅក្នុងភាពប្រថុយប្រថាន ឬស្រមើស្រមៃច្រើន។ ប៉ុន្តែព័ត៌មានដែលត្រូវប្រមូលនោះជាព័ត៌មានប្រភេទណាគឺផ្អែក ទៅលើបរិបទ និងគោលបំណងរបស់គម្រោង ឬផែនការ ដែលយើងចងរៀបចំ។

ឧទាហរណ៍ ប្រភេទព័ត៌មានដែលយើងត្រូវការសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និង កម្មវិធីវិនិយោគឃុំ/សង្កាត់រួមមាន៖

- ទីតាំងភូមិសាស្ត្រ
- ស្ថិតិប្រជាជន
- ស្ថានភាពសេដ្ឋកិច្ច (កម្រិតជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងចំណូលគ្រួសារ)
- ស្ថានភាពធនធានធម្មជាតិ និងបរិស្ថាន
- ស្ថានភាពកសិកម្ម
- ផ្នែកហេដ្ឋារចនាសម្ពន្ធ (ការអប់រំ សេវាសុខភាព គមនាគមន៍)
- ស្ថានភាពសន្តិសុខ
- ស្ថានភាពយេនឌ័រ (សមភាព និងសមធម៌រវាងបុរស និងស្ត្រី) និង
- ព័ត៌មានផ្សេងៗទៀត។

### ១.៦.២ ការប្រមូលព័ត៌មាន

ការប្រមូលពត៌មានជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ការរៀបចំផែនការ។ ការប្រមូលព័ត៌មានមានពីរប្រភេទសំខាន់ៗ៖ ការប្រមូលព័ត៌មានដែលមានស្រាប់ និងការប្រមូលព័ត៌មាននៅមូលដ្ឋានផ្ទាល់ ឬព័ត៌មានថ្មី

ដែលត្រូវប្រមូល។

❖ **ការប្រមូលព័ត៌មានដែលមានស្រាប់៖**

ព័ត៌មាន ឬឯកសារពាក់ព័ន្ធដែលមានស្រាប់គឺជាផ្នែកសំខាន់មួយដែលយើងត្រូវយកមកអាន និងវិភាគ ដើម្បីជាគន្លឹះក្នុងការរៀបចំផែនការព្រោះលទ្ធផលទាំងនោះ គឺជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យយើងឃើញនូវ បទពិសោធន៍ នានាដែលគួរ ឬពុំគួរយកជាគំរូសម្រាប់រៀបចំផែនការ។ ឯកសារទាំងនោះរួមមាន របាយការណ៍ ស្ថិតិ ស្រាវជ្រាវ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ត្រួតពិនិត្យ និងវាយតម្លៃ ខិតប័ណ្ណព្រឹត្តិបត្រ ។ល។ ដើម្បីទទួលបាន ព័ត៌មានទាំងនោះ យើងអាចប្រមូលពីស្ថាប័នពាក់ព័ន្ធនានាដែល បានចងក្រង និងបោះពុម្ពរួច។ ស្ថាប័នទាំងនោះ មានដូចជាស្ថាប័នរដ្ឋ *(ភូមិ ឃុំ មន្ទីរ ក្រសួង)* ស្ថាប័ន ឯកជន *(ក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាល)* សាកល វិទ្យាល័យ សាលារៀន។ល។

❖ **ការប្រមូលព័ត៌មាននៅមូលដ្ឋានផ្ទាល់ ឬព័ត៌មានថ្មីដែលត្រូវប្រមូល៖**

ជាទូទៅ ក្នុងការរៀបចំផែនការ គេត្រូវប្រមូលព័ត៌មាននៅមូលដ្ឋានផ្ទាល់ដោយប្រើនូវវិធីសាស្ត្រផ្សេងៗជា ច្រើន ដែលក្នុងនោះការវាយតម្លៃជនបទដោយមានការចូលរួម មានការពេញនិយមក្នុងការប្រើប្រាស់ដើម្បីប្រមូល ព័ត៌មានផ្សេងៗនៅមូលដ្ឋានដែលគេចង់បាន។ មានវិធានជាច្រើនរបស់ការវាយតម្លៃជនបទដោយ មានការចូលរួម ដែលគេតែងយកទៅប្រើ (**មើលវិធានទាំងនោះនៅ ផ្នែកទី៣**)។ ក្នុងការប្រមូលព័ត៌មាន ប្រភេទនេះ ជាដំបូងយើងត្រូវ កំណត់ទីតាំងភូមិសាស្ត្រ (ភូមិ ឃុំ ស្រុក) ពេលវេលា (ធ្វើនៅពេលណា រយៈពេលប៉ុន្មានថ្ងៃ) និងកំណត់ក្រុមគោល ដៅឱ្យបានច្បាស់លាស់ (ជាអ្នកក្រ អ្នកមធ្យម អ្នកធូរធារ ក្រុមបុរស ក្រុមស្ត្រី ឬក្រុមកុមារ ព្រះសង្ឃ ឬ គណៈកម្ម ការវត្ត គ្រូបង្រៀន) ជាមុនសិន។ ដើម្បីប្រមូល ព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយការកំណត់ឱ្យបានច្បាស់ពីបញ្ហា និង តម្រូវការរបស់ស្ត្រី បុរស និងក្រុម ងាយរងគ្រោះមានសារៈសំខាន់ខ្លាំងណាស់ ពីព្រោះផែនការនឹងអាចបម្រើផល ប្រយោជន៍ដល់ស្ត្រី បុរស និងក្រុមងាយរងគ្រោះឱ្យបានស្មើគ្នា ក្នុងការទទួលបានផលប្រយោជន៍។ លើសពីនេះ ទៀត បញ្ហា និងតម្រូវការរបស់អ្នកក្រីក្រ ឬក្រុមជនងាយរងគ្រោះ ក៏ត្រូវមានការគិតគូរឱ្យបានដិតដល់ផងដែរពីព្រោះ ប្រសិនបើយើងមិនបានគិតគូរដល់ពួកគាត់ទេនោះ ផែនការនោះនឹងអាចបម្រើបានតែប្រជាពលរដ្ឋដែលមានជីវភាព ធូរធារប៉ុណ្ណោះ។ បន្ទាប់មកត្រូវរៀបចំយុទ្ធសាស្ត្រ និងវិធីសាស្ត្រផ្សេងៗ ដើម្បីចុះប្រមូល ព័ត៌មាននៅគោលដៅដែល បានកំណត់ដោយយុទ្ធសាស្ត្រ ឬវិធីសាស្ត្រទាំងនោះអាចធ្វើជាការសម្ភាសន៍ ជាមួយប្រជាជនមូលដ្ឋានបែបក្រុម តូច ឬក្រុមធំ និងសម្ភាសន៍បុគ្គលសំខាន់ៗ ការសង្កេត និងសិក្ខាសាលា ដើម្បីផ្ទៀងផ្ទាត់ជាដើម។ល។

ដូចនេះ ដើម្បីឱ្យការប្រមូលព័ត៌មានរបស់យើងទទួលបានភាពជោគជ័យអ្នកប្រមូលព័ត៌មាន ត្រូវយល់ពី ក្រមសីធម៌ និងតម្លៃនៃអ្នកសម្ភាសន៍ដូចខាងក្រោម៖

❖ **គោលការណ៍របស់អ្នកសម្ភាសន៍**

ការសម្ភាសន៍ប្រព្រឹត្តទៅបានល្អ គឺទាមទាឱ្យអ្នកសម្ភាសន៍ត្រូវមានអាកប្បកិរិយា និងអត្តចរិក ត្រឹមត្រូវ។

- ត្រូវចេះគួរសម
- ត្រូវមានភាពស្និតស្នាល
- បង្ហាញនូវការចាប់អារម្មណ៍
- ត្រូវមានភាពទន់ភ្លន់
- ត្រូវចេះអត់ធ្មត់

ក្រៅពីអាកប្បកិរិយា និងអត្តចរិកដ៏ល្អនោះ អ្នកសម្ភាសន៍ត្រូវដឹងពីតួនាទីរបស់ខ្លួននៅពេលដែលអនុវត្តន៍។

- មកស្តាប់ (មិនមែនមកធ្វើសន្ទនា ឬឧទ្ទេសនាមទេ)

- មករៀន (មិនមែនមកបង្រៀនទេ)
- មកសម្របសម្រួល (មិនមកបញ្ជាទេ)។

❖ **អ្វីដែលត្រូវធ្វើ នៅពេលសម្ភាសន៍**

| *អ្វីត្រូវធ្វើនៅពេលសម្ភាសន៍* |
| --- |
| - ត្រូវគិតថាខ្លួនយើងជាអ្នកមករៀនសូត្រ<br>- ត្រូវទុកឋានៈ សមិទ្ធកម្ម និងបទពិសោធន៍មួយអន្លេសីនិ |
| - ត្រូវឆាប់យល់ពីអារម្មណ៍របស់អ្នកភូមិ (ការខឹងសំបារ ការផុនទ្រាន់ ការឈឺចាប់ សេចក្តីសាទរ<br>- ត្រូវប្រុងប្រយ័ត្ន ត្រូវរិះរកគំនិត និងមធ្យោបាយដែលត្រូវដឹកនាំធ្វើការបន្តទៅទៀត |
| - ត្រូវធ្វើតាមពិធីការដោយណែនាំខ្លួនអ្នកឱ្យគេស្គាល់<br>- ប្រាប់ពីមូលហេតុដែលនាំឱ្យអ្នកមកទីនេះហើយត្រូវសួរនាំពួកគេសិន បើសិនជាគ្មានការយល់ជំទាស់អ្វីទេនោះ |
| - ជួយសម្រួលក្នុងការសម្ភាសន៍ |
| - បង្កើតអោយមានបរិយាកាសជឿជាក់ ទុកចិត្ត និងសប្បាយរីករាយ<br>- ត្រូវចាំថាពួកគេម្នាក់ៗ ក៏មានរឿងមកនិយាយដែរ<br>- ត្រូវប្រាស្រ័យទាក់ទងជាមួយអ្នកនៅស្ងាត់ស្ងៀម ជាពិសេសស្ត្រី<br>- ជៀសវាងការសន្ទនាតែម្នាក់ (នៅក្នុងករណីនេះអ្នកត្រូវរកមធ្យោបាយនាំអ្នកដែលនិយាយច្រើនចេញដើរទៅក្រៅដើម្បីទុកពេលឱ្យអ្នកផ្សេងទៀតបន្តការពិភាក្សាដោយគ្មានការរំខាន |
| - ស្តាប់ដោយប្រុងប្រយ័ត្ន ហើយជួយសម្រួលឱ្យនៅតែមានការបញ្ចេញយោបល់ |
| - ត្រូវឱ្យមានការត្រួតពិនិត្យ និងសួរបញ្ជាក់ព័ត៌មានបន្ថែមពីអ្នកភូមិ |
| - ត្រូវបញ្ចប់ការសម្ភាសន៍ណាដែលមិនល្អ ដោយសម្រលួ កុំគិតថាវាជាការងារអាក្រក់នោះ ប៉ុន្តែត្រូវខិតខំវិភាគឡើងវិញនូវអ្វីដែលនាំឱ្យខុសគ្នា |
| - ត្រូវកត់ឈ្មោះអ្នកផ្តល់ព័ត៌មានទុក ហើយឱ្យតម្លៃ ឬលើកទឹកចិត្តពួកគេចំពោះព័ត៌មានដែលពួកគេផ្តល់ឱ្យ |

# ផ្នែកទី២៖ ឧបករណ៍មួយចំនួនសម្រាប់ការប្រមូលព័ត៌មានដើម្បីរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ/សង្កាត់

## ២.១ គោលគំនិតទូទៅរបស់ការវាយតម្លៃជនបទដោយមានការចូលរួម

ការវាយតម្លៃជនបទដោយមានការចូលរួម ជាដំណើរការរៀនសូត្រដ៏ស៊ីជម្រៅដែលមានលក្ខណៈជាប្រព័ន្ធ ហើយជាញឹកញាប់ត្រូវបានអនុវត្តនៅក្នុងសហគមន៍ដោយក្រុមអ្នកជំនាញនិងរួមបញ្ចូលទាំងអ្នកទទួលផលសំខាន់ៗ ពីសហគមន៍ដើម្បីទទួលបាន និងវិភាគនូវទិន្នន័យប្រកបដោយប្រសិទ្ធភាពទៅលើលក្ខខណ្ឌសហគមន៍ក្នុងគោល- បំណងធ្វើការចងក្រងនូវព័ត៌មានដែលមានប្រយោជន៍ អាចទុកចិត្តបាន និងទាន់ពេលវេលា។ ទន្ទឹមនឹងនេះដែរការ វាយតម្លៃជនបទដោយមានការចូលរួមអាចបង្កើតឱ្យមានដំណើរការចូលរួមពិភាក្សា ទំនាក់ទំនង រកដំណោះស្រាយទំនាស់ និងជាការផ្ទេរសិទ្ធិអំណាចដល់ប្រជាជនក្នុងតំបន់ ដើម្បីផ្លាស់ប្តូរនូវស្ថានភាព និងលក្ខខណ្ឌនានាដោយ ខ្លួនពួកគេផ្ទាល់។ ម្យ៉ាងវិញទៀត ការធ្វើការវាយតម្លៃជនបទដោយមានការចូលរួមអាចផ្តល់លទ្ធភាពឱ្យពួកគេធ្វើ ការវិភាគដោយខ្លួនឯងផ្ទាល់ដើម្បីឈានដល់ការរៀបចំផែនការ និងអនុវត្តសកម្មភាព ។

❖ **និយមន័យការវាយតម្លៃជនបទដោយមានការចូលរួម**

ការវាយតម្លៃជនបទដោយមានការចូលរួម គឺជាការប្រមូលព័ត៌មានដោយមានការចូលរួមពីសហគមន៍សម្រាប់ការងារអភិវឌ្ឍន៍ និងដែលអាចធ្វើឱ្យសហគមន៍រៀបចំផែនការ និងចូលរួមក្នុងការអនុវត្តសកម្មភាពនានានៅថ្ងៃអនាគត។

❖ **គោលបំណងរបស់ ការវាយតម្លៃជនបទដោយមានការចូលរួម**

ការវាយតម្លៃជនបទដោយមានការចូលរួម ធ្វើឡើងក្នុងគោលបំណង៖

- ដើម្បីធ្វើការវិភាគនូវស្ថានភាពបច្ចុប្បន្ន និងសក្តានុពលនៅក្នុងភូមិ ឬសហគមន៍
- ដើម្បីវិភាគបញ្ហា និងមូលហេតុដែលកើតមាននៅក្នុងភូមិ ឬសហគមន៍
- ដើម្បីជួយដល់គ្រួសារនីមួយៗក្នុងការកំណត់នូវសកម្មភាពនានា ដែលឆ្លើយតបទៅនឹងការពិបាក និង ឱកាសរបស់ពួកគេ។

❖ **គោលការណ៍របស់ ការវាយតម្លៃជនបទដោយមានការចូលរួម**

- រៀន និងស្វែងរកព័ត៌មានបានឆាប់រហ័ស តាមលក្ខណៈវិនិច្ឆ័យរបស់សហគមន៍មូលដ្ឋាន
- ជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋផ្ទាល់ក្នុងមូលដ្ឋាន
- ប្រើប្រាស់វិធីសាស្ត្រចម្រុះដើម្បីប្រមូលព័ត៌មានពីប្រភព និងទីតាំងផ្សេងៗគ្នា
- មានភាពបត់បែនទៅតាមស្ថានភាព និងកាលៈទេសៈ
- មានការវិភាគ និងចែករំលែកព័ត៌មានជាមួយសហគមន៍មូលដ្ឋាន និង
- ទទួលស្គាល់ និងរៀនពីកំហុសព្រមទាំងធ្វើការកែលំអឱ្យប្រសើរឡើង។

❖ **ផលប្រយោជន៍របស់ ការវាយតម្លៃជនបទដោយមានការចូលរួម**

- ការផ្តល់សិទ្ធិអំណាចដល់ប្រជាជនក្នុងតំបន់
- ការប្រកាន់ភ្ជាប់នូវការចូលរួមយ៉ាងសកម្មពីសហគមន៍
- ការអភិវឌ្ឍ និងការទទួលយកនូវចំណេះដឹង ការលើទឹកចិត្ត ឬផ្តល់លទ្ធភាពដល់ការបង្ហាញនូគំនិត និងភាពខុសគ្នាក្នុងតំបន់
- ការចែករំលែកនូវចំណេះដឹងពីគ្នាទៅវិញទៅមកជាមួយសមាជិកសហគមន៍
- ការកំណត់នូវអាទិភាពក្នុងការស្រាវជ្រាវ
- ការកំណត់នូវកម្មវិធីផ្សព្វផ្សាយដោយមានការចូលរួម និង
- ការរៀបចំគោលនយោបាយ។
-

❖ **ហានិភ័យរបស់ការវាយតម្លៃជនបទដោយមានការចូលរួម**

- សមាជិកក្រុមខ្វះបទពិសោធន៍លើជំនាញទំនាក់ទំនង សម្របសម្រួល និងដោះស្រាយទំនាស់
- សមាជិកក្រុមសម្តែងនូវអត្តចរិតមិនសមស្រប ពិបាកទំនាក់ទំនង និងមិនមានការគោរព មានទំនោរទៅរកទិន្នន័យបែបបរិមាណ និងស្ថិតិដែលផ្តល់ឱ្យតាមរយៈបញ្ជីសំណួរ
- ពិបាកក្នុងការទទួលបានព័ត៌មានពិតប្រាកដ ដោយសារព័ត៌មានមួយចំនួនត្រូវបានគេផ្តល់ឱ្យហួសពីការ ពិតទៅតាមការចាប់អារម្មណ៍របស់បុគ្គលម្នាក់ៗ
- មើលរំលង និងមិនសូវយកចិត្តទុកដាក់លើស្ត្រី កុមារ ជនក្រីក្រ អ្នកដែលមានមានចំណេះដឹងតិចតួច អ្នកមានអាយុតិច អ្នកគ្មានដីធ្លី ក្រុមជនជាតិដើមភាគតិច និងក្រុមសាសនា
- អ្នកចូលរួមអនុវត្តសកម្មភាពក្នុងដំណើរការស្រាវជ្រាវ ការវាយតម្លៃជនបទដោយមានការចូលរួមមិនមានលក្ខណៈអព្យាក្រិត
- ការអនុវត្តការវាយតម្លៃជនបទដោយមានការចូលរួមដោយគ្មានការផ្ទៀងផ្ទាត់នូវទិន្នន័យ។

## ២.២ ឧបករណ៍សម្រាប់ការប្រមូលព័ត៌មានដោយមានការចូលរួម

ឧបករណ៍សម្រាប់ការប្រមូល**ព័ត៌មានដោយមានការចូលរួម** មានជាច្រើនប្រភេទ ដែលយើងអាចប្រើប្រាស់សម្រាប់ការប្រមូល**ព័ត៌មាន**ដោយមានការចូលរួម ទៅតាមគោលបំណងដែលយើងចង់បាន។ ក៏ប៉ុន្តែនៅក្នុងមេរៀនការធ្វើផែនការដោយមានការចូលរួមនេះ សូមលើកយកតែឧបករណ៍មួយចំនួនមកធ្វើការបង្ហាញដើម្បីឱ្យអ្នកចូលរួមមានមូលដ្ឋានក្នុងការប្រមូល**ព័ត៌មាន**សម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ៖

- ✓ ការអនុវត្តក្នុងការសួរដេញដោល (រកហេតុផល)
- ✓ ការគូសផែនទីដោយមានការចូលរួម
- ✓ ប្រតិទិនរដូវកាល
- ✓ ការវិភាគអ្នកពាក់ព័ន្ធ
- ✓ ការចាត់ចំណាត់ថ្នាក់បញ្ហា
- ✓ ការវិភាគដើមឈើបញ្ហា
- ✓ ការស្វែងយល់ពីទស្សនវិស័យ
- ✓ ការវិភាគពីតម្រូវការ និង
- ✓ វិភាគឧបសគ្គ និងដំណោះស្រាយ

### ២.២.១ ការអនុវត្តក្នុងការសួរដេញដោល (រកហេតុផល)

ជាទូទៅការអនុវត្តក្នុងការសួរដេញដោលត្រូវបានគេប្រើប្រាស់ដើម្បីស្វែងរកហេតុផល។ ក្នុងនាមជាអ្នកសម្របសម្រួលម្នាក់ ការប្រើសំណួរសួរដេញដោលត្រូវតែប្រើតាមលក្ខណៈជំនាញ និងប្រកបដោយគុណធម៌។ តើការសួរដេញដោលជាអ្វី?

ការសួរដេញដោលគឺជាការសួរសំណួរតាមដាន ដើម្បីទទួលយកការយល់ដឹងឱ្យបានច្រើនដូចជា៖

- តើអ្នកអាចពន្យល់បន្ថែមបានទេ?
- តើអ្នកអាចពន្យល់តាមរបៀបផ្សេងបានទេ?
- តើអ្នកអាចប្រាប់ខ្ញុំឱ្យបានច្រើនអំពីវាបានទេ?
- ក៏ប៉ុន្តែ ហេតុអ្វី របៀបណា នរណា នៅពេលណា នៅទីកន្លែងណា? និង
- មានអ្វីបន្ថែមទៀតដែរឬទេ?

ការសួរដេញដោលប្រៀបដូចជាការបកស្រទាប់ខ្ទឹមបារាំងដែរ។ មានន័យថាដោយធ្វើការសួរដេញដោលអ្នកសម្របសម្រួលអាចចូលកាន់តែជិតទៅនឹងមូលហេតុពិតប្រាកដដែលមាននៅពីក្រោយអ្វីមួយ ឬទទួលបានការយល់ដឹងកាន់តែច្រើន។

ហេតុអ្វីបានជាការសួរដេញដោលជាជំនាញសំខាន់មួយសម្រាប់អ្នកសម្របសម្រួល ហើយគេអាចប្រើវា *នៅពេលណា?*

ការសួរដេញដោលមានគោលបំណងផ្សេងៗជាច្រើន ។ គេអាចប្រើវាដើម្បី៖

- ធ្វើឱ្យមនុស្សបញ្ចេញគំនិតមកក្រៅ
- ធ្វើឱ្យកាន់តែយល់ពីសំណួរ ការចូលរួមយោបល់ ឬ គំនិត
- បង្កើតការជជែកវែកញែក និង
- ដោះស្រាយបញ្ហាផ្សេងៗ

តើត្រូវធ្វើការសួរដេញដោលឱ្យល្អយ៉ាងណា?

| អ្វីដែលត្រូវធ្វើ | អ្វីដែលមិនត្រូវធ្វើ |
|---|---|
| - ស្តាប់យ៉ាងយកចិត្តទុកដាក់<br>- បង្កើតសំណួរបន្ទាប់អំពីការយល់ដឹងលើ ចម្លើយដែលបានឆ្លើយ<br>- បញ្ជាក់ព័ត៌មានឱ្យបានច្បាស់<br>- ជ្រើសយកបញ្ហា ឬចំណុចសំខាន់ | - វិនិច្ឆ័យពេលស្តាប់<br>- ផ្លោះពីប្រធានបទ ឬបញ្ហាមួយទៅមួយទៀត<br>- ធ្វើការសន្មត<br>- ចាកពីប្រធានបទដោយសារតែជាប់គាំងក្នុងការវែកញែកពិស្តារ |

### ២.២.២ ការគូរផែនទីដោយមានការចូលរួម

❖ **គោលបំណង**

ការប្រើប្រាស់វិធីសាស្ត្រនេះ គឺយើងចង់បានព័ត៌មានដែលទាក់ទងទៅនឹងស្ថានភាពភូមិសាស្ត្រ ប្រភពធនធានផ្សេងៗ និងទីតាំងតំបន់ប្រើប្រាស់ធនធាននីមួយៗ ដែលមាននៅក្នុងសហគមន៍។ វិធីសាស្ត្រនេះភាគច្រើន

ធ្វើការអនុវត្តមុនគេក្នុងដំណើរការសិក្សាស្រាវជ្រាវនៅមូលដ្ឋាន។



❖ **ដំណើរការក្នុងការអនុវត្ត**

១- ជ្រើសរើសអ្នកដែលអាចផ្តល់ព័ត៌មាន ពី ១០ ទៅ ១៥ នាក់

២- បង្ហាញពីគោលបំណងដល់អ្នកចូលរួម

៣- ធ្វើការសម្រេចចិត្តលើប្រភេទផែនទីដែលត្រូវគូរ (ធនធានធម្មជាតិ កសិដ្ឋាន ហេដ្ឋារចនាសម្ពន្ធ)

៤- ជ្រើសរើសទីតាំងសមស្របដែលអាចមើលឃើញនូវស្ថានភាពភូមិសាស្ត្រក្នុងតំបន់

៥- ព្យាយាមរកអ្នកដែលស្គាល់ពីស្ថានភាពភូមិសាស្ត្រច្បាស់លាស់ និងមានឆន្ទៈចូលរួមចែករំលែកចំណេះដឹងជាមួយអ្នកដទៃ។ ផែនទីនេះគួរតែអ្នកភូមិជាអ្នកគូសដោយខ្លួនឯង ឬធ្វើការសហការជិតស្និទ្ធជាមួយពួកគាត់ក្នុងការគូស។

៦- ផ្តើមចេញពីចំណុចគោលណាមួយច្បាស់លាស់ ឬងាយយល់ ដោយប្រើប្រាស់វត្ថុសម្គាល់ទៅតាម លទ្ធភាពដែលមាន ឬអាចរកបាននៅជុំវិញទីនោះ ដូចជាថ្ម គ្រួស ឬស្លឹកឈើ ។ល។ (ក្នុងករណីធ្វើនៅ លើដី) ឬប្រើប៊ិច ឬហ្វឺត (ក្នុងករណីប្រើក្រដាស់ផ្ទាំងធំ)។

៧- កំណត់សញ្ញាសម្គាល់នៅលើផែនទីព្រាង

៨- អ្នកសម្របសម្រួលប្រើសំណួរម្តងមួយៗ តើប្រភេទធនធាននីមួយៗមានទំហំប៉ុនណា និងនៅកន្លែង ណាខ្លះ....? ទៅតាមលំដាប់លំដោយដែលទាក់ទងទៅនិងធនធានធម្មជាតិ អាគារ ហេដ្ឋារចនាសម្ព័ន្ធ ជាដើម ដោយសរសេរឈ្មោះលើទីតាំងសំខាន់ៗ ដូចជា ទីតាំងភូមិ ផ្លូវ និង ព្រៃ អូរ បឹង....។

៩- នៅពេលពួកគាត់aឈប់គូសហើយ អ្នកសម្របសម្រួលត្រូវសួរទៅកាន់អ្នកចូលរួមថា *តើផែនទីនេះ មានលក្ខណៈពេញលេញហើយឬនៅ? តើផែនទីនេះបានបង្ហាញនូវចំណុចសំខាន់ៗអស់ហើយ ឬនៅ នៅក្នុងភូមិរបស់ពួកគាត់?តើមានអ្វីសំខាន់ផ្សេងទៀតដែលគួរបន្ថែមនៅលើផែនទីនេះទេ?*

១០- ចម្លងផែនទីព្រាងដាក់លើក្រដាស់ផ្ទាំងធំដោយកំណត់ទិស (ខាងជើង ខាងត្បូង ខាងកើត ខាង លិច) និងនិមិត្តសញ្ញា ហើយកត់ឈ្មោះអ្នកចូលរួម និងថ្ងៃខែផង។

ឧទាហរណ៍៖ ការគូសផែនទីដោយមានការចូលរួមដែលធ្វើនៅលើដីផ្ទាល់




ផែនទីដោយមានការចូលរួមរបស់ភូមិស្រែធំ ឃុំរុងរឿង ស្រុករវៀងខេត្តព្រះវិហារ
ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧




អ្នកចូលរួម
១ស៊ុន ម៉ៅ (ស) ២- គង់ ស៊ំ (ស)
៣-ភោគ យ៉ាន (ស) ៤- គ្រួច សន (ស)
៥- ជា ផេង (ប) ៦-ស៊ុន ហួន (ប)
៧- សៅ ស៊ុយ (ប) ៨- ស៊ុន យាម (ប)
៩- ចាន់ សៃ (ប) ១០-ព្រំ រឹម (ប)
១១-ហែម ហំ (ប) ១២- ចាន់ ជុំ (ប)
១៣ សឹង សាមិត្ត (ប) ១៤-ប៊ុន លុន (ប)

សញ្ញាសម្គាល់
- ស្រែ
- ផ្លូវលំ
- ផ្លូវរទេះ
- អូរ
- សាលារៀន
- ផ្ទះ
- តំបន់ព្រៃច្បោះដរ
- តំបន់ស្រូវចំការ
- ចំការសណ្ដែងសៀង
- ចំការស្វាយចាន់ទី
- ត្រពាំង

❖ **ចំណុចគួរចងចាំ**

- គួរបត់បែនទៅតាមកាលៈទេសៈ និងចេះបន្ទូរបរិយាកាស
- កំណត់ទិស និងនិមិត្តសញ្ញា
- កត់ឈ្មោះអ្នកចូលរួម និងថ្ងៃខែ
- កំណត់ប្រភេទធនធានដែលចង់សិក្សានៅលើផែនទីឱ្យបានច្បាស់លាស់
- សម្របសម្រួលឱ្យមានការចូលរួមបញ្ចេញមតិឱ្យបានគ្រប់គ្នាទាំងបុរស និងស្ត្រី។

❖ **ចំណុចគួរចៀសវាង**

- កុំប្រើសំណួរផ្ទួនៗ ឬប្រើសំណួរលោតចុះលោតឡើង
- កុំទាមទារនូវខ្នាតជាក់លាក់
- មិនត្រូវសម្តែងនូវការបដិសេធនៅចំពោះមុខ
- មិនត្រូវឱ្យមានគំនិតណាមួយលប់លើគំនិតអ្នកដទៃ

## ២.២.៣ ប្រតិទិនរដូវកាល

❖ **គោលបំណង**

ការប្រើប្រាស់វិធីសាស្ត្រនេះដើម្បីកំណត់ឱ្យឃើញនូវព័ត៌មានដែលទាក់ទងនឹងសកម្មភាពរួមរបស់សហគមន៍ ក្នុងរយៈពេលពេញមួយឆ្នាំ ជាពិសេសគឺបញ្ជាក់ឱ្យដឹងថា តើប្រជាជនមានសកម្មភាពអ្វីខ្លះ ដែលទាក់ទងទៅនឹងការ ចិញ្ចឹមជីវិតនៅក្នុងខែណា? រដូវណា?។ ម៉្យាងទៀតយើងក៏បានដឹងផងដែរនូវពេលវេលាដែលសហគមន៍អាចទំនេរ ដែលជាលក្ខណៈងាយស្រួលក្នុងការធ្វើសកម្មភាពផ្សេងៗរបស់ក្រុមការងារ ព្រោះយើងតម្រូវឱ្យមានការចូលរួមពី សហគមន៍មូលដ្ឋាន។

❖ **ដំណើរការក្នុងការអនុវត្ត**

១- ជ្រើសរើសអ្នកដែលអាចផ្តល់ព័ត៌មាន ពី ១០ ទៅ ១៥ នាក់

២- បង្ហាញពីគោលបំណងដល់អ្នកចូលរួម

៣- ធ្វើតារាងសកម្មភាព និងពេលវេលាទៅតាមទម្លាប់ប្រើរបស់សហគមន៍ ជាទម្រង់តារាងដោយកំណត់ ជួរដេកជាខែ ហើយជួរឈរជាប្រភេទសកម្មភាព។

ឧទាហរណ៍ ៖ **តារាងប្រតិទិនរដូវកាល**

| សកម្មភាព | មិគសិរ | បុស្ស | មាឃ | ផល្គុន | ចេត្រ | ពិសាខ | ជេស្ឋ | អាសាធ | ស្រាពណ៍ | ភទ្របទ | អស្សុជ | កត្តិក |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ធ្វើស្រែ | | | | | | | | | | | | |
| នេសាទ | | | | | | | | | | | | |

៤- ឱ្យសហគមន៍លើកឡើងពីសកម្មភាពសំខាន់ៗ ដែលជាលក្ខណៈរួមនៅក្នុងភូមិដូចជា ធ្វើស្រែ ធ្វើចំការ ឡើងត្នោត នេសាទ ដាំបន្លែ ចិញ្ចឹមសត្វ កម្ពស់ទឹកភ្លៀង និងភាពរាំងស្ងួត និងសកម្មភាពផ្សេងៗទៀត អាស្រ័យលើគោលបំណងនៃការសិក្សា

៥- ស្នើឱ្យអ្នកចូលរួមធ្វើការកំណត់នូវសកម្មភាពចម្បងៗហើយចម្លងចូលតារាងតាមលំដាប់

លំដោយ

៦- កំណត់ពេលវេលារបស់សកម្មភាពលំអិតនីមួយៗនៅក្នុងសកម្មភាពធំ (ធ្វើស្រែ ភ្ជួរ រាស់ ដកស្ទូង ប្រមូលផល...នៅពេលណាដោយមានការឯកភាពរួមរវាងអ្នកផ្តល់ព័ត៌មាន

៧- រួចគូរបន្ទាត់ពេលវេលាទាំងនោះទៅលើតារាងប្រតិទិនរដូវកាលទៅតាមស្ថានភាពជាក់ស្តែង

៨- កំណត់និមិត្តសញ្ញា និងរូបភាពឱ្យបានច្បាស់លាស់

៩- អ្នកសម្របសម្រួលធ្វើការសង្ខេបនូវលទ្ធផលដោយគូសបញ្ជាក់ពីកំឡុងពេលណាដែលប្រជាជនមានការមមាញឹកក្នុងការប្រកបរបរចិញ្ចឹមជីវិត និងពេលទំនេរដែលអាចចូលរួមក្នុងការងារគម្រោង

១០- កត់ឈ្មោះអ្នកចូលរួម និងកាលបរិច្ឆេទ។



❖ **ចំណុចគួរចងចាំ**

- ប្រើប្រាស់សម្ភារដែលអាចរកបាននៅក្នុងតំបន់ដូចជា៖ កំណាត់ឈើ ឬដុំថ្មតូចៗ ឬគ្រាប់សណ្តែកសម្រាប់ដាក់ជានិមិត្តសញ្ញា (ក្នុងករណីធ្វើនៅលើដី) ឬប្រើប៊ិច ឬហ្វឺត (ក្នុងករណីប្រើក្រដាស់ផ្ទាំងធំ)។
- គួរបត់បែនទៅតាមកាលៈទេសៈ
- កំណត់ប្រភេទព័ត៌មានដែលចង់សិក្សានៅលើតារាងឱ្យបានច្បាស់
- ត្រូវចេះបន្ធូរបរិយាកាស
- ត្រូវពិចារណាទៅលើទម្លាប់ ជាទូទៅនៅក្នុងតំបន់នៃវដ្តផលិតកម្ម
- ថ្ងៃខែនៃការអនុវត្ត និងបញ្ជាក់សញ្ញាសម្គាល់

❖ **ចំណុចគួរជៀសវាង**

- កុំយកសកម្មភាពជាលក្ខណៈបុគ្គល និងកុំយកសកម្មភាពលម្អិតពេក
- កុំទាមទារយកពេលវេលាជាក់លាក់
- មិនត្រូវឱ្យមានគំនិតណាមួយលប់លើគំនិតអ្នកដទៃ

## ឧទាហរណ៍ ៖ការធ្វើប្រតិទិនរដូវកាល



### តារាងបំពេញប្រតិទិនរដូវកាលគំរូ

តារាងប្រតិទិនរដូវកាលរបស់ភូមិព្រៃយ៉ាវឃុំស្រែក្នុង ស្រុកជុំគីរី ខេត្តកំពត(ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០០)

| | មិគសិរ | បុស្ស | មាឃ | ផល្គុន | ចេត្រ | ពិសាខ | ជេស្ឋ | អាសាធ | ស្រាពណ៍ | ភទ្របទ | អស្សុជ | កត្តិក |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | គុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ស្រូវស្សា | — | | | | | | | — | — | — | — | — |
| ស្រូវចំការ | | | | — | — | | | | | — | | |
| កាប់ឈើ | | — | — | — | — | | | | | | | |
| ពោត | | | | — | — | — | | | | | | |
| សណ្តែកដី | | | | — | — | — | — | | | | | |
| ឪឡឹក | — | | | | | | | | | | — | — |
| រកអុស | — | — | — | — | — | — | — | — | — | — | — | |
| ឡើងត្នោត | — | — | — | — | | | | | | | — | — |
| ដំឡូងជ្វា | | | | | | | | | | — | — | — |
| សណ្តែកបាយ | | | | — | — | — | — | | | | | |
| កាប់រានដី | | | — | | | | | | | | | |
| លែងគោ | — | — | — | — | — | — | — | — | — | — | — | |
| ជំងឺសត្វគោ | | | | — | — | | | | | | | |
| ជំងឺមាន់ | — | — | — | — | — | — | — | — | — | — | — | — |
| ជំងឺមនុស្ស | | | | | | — | — | — | — | — | | |
| លក់កម្លាំង | | — | — | | | | | | | | | |
| ខ្វះស្បៀង | | | | | | | | | — | — | | |

កំណាត់សម្គាល់៖ ▬▬ (មិនសូវរស់) ▬▬ រស់ (មមាញឹក)
អ្នកចូលរួម៖
- លោក វ៉ាន់ ស៊ិន (មេភូមិ)
- ព្រឹទ្ធាចារ្យ គឹម លួន
- លោក ឈឹម ស៊ុនលី

## ២.២.៤ ការវិភាគអ្នកពាក់ព័ន្ធ

❖ **គោលបំណង**

- ដើម្បីកំណត់ដៃគូសំខាន់ៗ ក្នុងការងារអភិវឌ្ឍ
- ដើម្បីស្វែងយល់ឬស្រាវជ្រាវនូវរបៀបផ្សេងៗដែលអាចយកទៅប្រើប្រាស់បាននៅក្នុងការទំនាក់ទំនង ជាមួយនឹងជនណាម្នាក់ ឬក្រុមណាមួយដែលអាចជាអ្នកគាំទ្រ ឬជាអ្នកប្រឆាំងចំពោះកិច្ចការអ្វីមួយ
- ដើម្បីធ្វើការប៉ាន់ប្រមាណនូវស្ថានភាពលើ ការទំនាក់ទំនង ការចាប់អារម្មណ៍ សិទ្ធិអំណាច និងឥទ្ធិពល របស់អ្នកពាក់ព័ន្ធនៅក្នុងសហគមន៍។

❖ **ដំណើរការក្នុងការអនុវត្ត**

១- ជ្រើសរើសអ្នកចូលរួម ពី ១០ ទៅ ១៥ នាក់
២- បង្ហាញពីគោលបំណងដល់អ្នកចូលរួម
៣- ឱ្យអ្នកចូលរួមលើកឡើងពីអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងភូមិ ដូចជា អង្គភាព/អង្គការ និងបុគ្គលសំខាន់ៗ ដែលមានទំនួលខុសត្រូវឬពាក់ព័ន្ធលើការសម្រេចចិត្តនៅក្នុងភូមិ ឬសហគមន៍។
៤- គូសរង្វង់ជុំវិញឈ្មោះស្ថាប័ន អង្គភាព ឬ បុគ្គលសំខាន់ៗដែលទំហំរង្វង់បង្ហាញពីសិទ្ធិ និងសេចក្តីសម្រេចចិត្ត បន្ទាប់មកគូរទំហំត្រីកោណពីលើរង្វង់នោះដែលបង្ហាញពីអំណាច ហើយគម្លាតនៃរង្វង់ បង្ហាញពីទំនាក់ទំនងនៅក្នុងសហគមន៍។
៥- វិភាគរួមគ្នាលើអ្នកពាក់ព័ន្ធម្តងមួយៗ ដោយបញ្ជាក់ជាមួយអ្នកចូលរួមថាតើស្ថាប័នណា ឬបុគ្គលណាដែលអាចជួយអ្នកបានច្រើននៅក្នុងការអនុវត្តសកម្មភាពផ្សេងៗ។

**ឧទាហរណ៍**




- គម្លាតនៃរង្វង់បង្ហាញពីទំនាក់ទំនង
- ទំហំរង្វង់បង្ហាញពីសិទ្ធិ និងសេចក្តី សម្រេចចិត្ត
- ទំហំត្រីកោណបង្ហាញពីអំណាច

❖ **ចំណុចគួរចងចាំ**

- គួរបត់បែនទៅតាមកាលៈទេសៈ
- ត្រូវចេះបន្ធូរបរិយាកាស
- ត្រូវគ្រប់គ្រងនូវការពិភាក្សានៅពេលដែលអ្នកចូលរួម និយាយអាក្រក់ពីស្ថាប័នណាមួយ

❖ **ចំណុចគួរជៀសវាង**

- កុំប្រើសំណួរផ្ទួនៗ និង លោតចុះ លោតឡើង
- មិនត្រូវសម្តែងនូវការបដិសេធនៅចំពោះមុខ
- មិនត្រូវឱ្យមានគំនិតណាមួយលប់លើគំនិតអ្នកដទៃ

### ២.២.៥ ចំណាត់ថ្នាក់បញ្ហា

❖ **គោលបំណង**

ដើម្បីជួយឱ្យប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំ កំណត់បាននូវបញ្ហា និងចាត់អាទិភាពបញ្ហារបស់ពួកគេដោយ

ផ្តោតការយកចិត្តទុកដាក់ពីវិសាលភាព និងផលប៉ះពាល់នៃបញ្ហា។

❖ **ដំណើរការក្នុងការអនុវត្ត ៖**

១- បង្ហាញពីគោលបំណងដល់អ្នកចូលរួម

២- បែងចែកអ្នកចូលរួមជាបីក្រុម គឺ ក្រុមស្ត្រី ក្រុមបុរស និងក្រុមងាយរងគ្រោះ (មួយក្រុមមានអ្នកចូល រួមពី ១០-១៥ នាក់)ហើយក្រុមនីមួយៗត្រូវអនុវត្តតាម ជំហានដូចខាងក្រោម (ពីជំហាន ៣-៨)

៣- អ្នកសម្របសម្រួល បំផុសគំនិតជាមួយអ្នកចូលរួមដោយសួរនូវសំណួរដូចតទៅនេះ "**តើមានបញ្ហាអ្វីខ្លះដែលកើតឡើងនៅក្នុង ភូមិ ឬឃុំរបស់អ្នក**?"

៤- សរសេរចម្លើយអ្នកចូលរួមទាំងអស់ដាក់លើក្រដាស ហើយអ្នកសម្របសម្រួលធ្វើការចាត់បញ្ហាដែលដូច ឬស្រដៀងគ្នានៅក្នុងក្រុមតែមួយ ឬក្រុមខុសគ្នា (យ៉ាងច្រើន៥បញ្ហា) រួចហើយអ្នកសម្របសម្រួលសរសេរបញ្ហាទាំងនោះចូលតារាងប្រៀបធៀប។

៥- អ្នកសម្របសម្រួលបំផុសឱ្យអ្នកចូលរួមចាត់អាទិភាពនៃបញ្ហា ដោយបង្ហាញពី លក្ខណៈវិនិច្ឆ័យដើម្បី កំណត់លំដាប់រៀងនៃបញ្ហានានាដូចជា៖

- បញ្ហាទាំងនោះមាន វិសាលភាព ឬទំហំធំ (ប្រជាពលរដ្ឋភាគច្រើនទទួលរងផលប៉ះពាល់ពីបញ្ហា នោះ)។ ឧទាហរណ៍៖ ផលនេសាទថយចុះ
- បញ្ហាទាំងនោះកើតមានយូរមកហើយ មិនទាន់មានដំណោះស្រាយនៅឡើយ
- តើបញ្ហានោះកើតឡើងជាទៀងទាត់ ឬទេ? ក្នុងកំឡុងរដូវណា?

៦- អនុញ្ញាតឱ្យអ្នកចូលរួមធ្វើការវិភាគបញ្ហានីមួយៗ ដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យដែលបាន កំណត់ រួចចាប់ផ្តើមកំណត់រកអាទិភាពរបស់វាដោយប្រើតារាងខាងក្រោមសម្រាប់ធ្វើអាទិភាពបញ្ហា (សំណួរសម្រាប់ធ្វើការបោះឆ្នោតៈ តើផលត្រីថយចុះ និងដីខ្សោះជីជាតិមួយណាសំខាន់ជាង? បើគិតថាផល ត្រីថយចុះសំខាន់ជាងសូមលើកដៃ)។

| ផលត្រីថយចុះ | ដីខ្សោះជីជាតិ | ខ្វះផ្លូវថ្នល់ | ខ្វះអណ្តូងទឹក | ខ្វះមុខរបរ | | ពិន្ទុ | លំដាប់ថ្នាក់ |
|---|---|---|---|---|---|---|---|
| | ផលត្រីថយចុះ | ផលត្រីថយចុះ | ផលត្រីថយចុះ | ខ្វះមុខរបរ | ផលត្រីថយចុះ | ៣ | ខ |
| | | ខ្វះផ្លូវថ្នល់ | ដីខ្សោះជីជាតិ | ខ្វះមុខរបរ | ដីខ្សោះជីជាតិ | ១ | ឃ |
| | | | ខ្វះផ្លូវថ្នល់ | ខ្វះមុខរបរ | ខ្វះផ្លូវថ្នល់ | ២ | គ |
| | | | | ខ្វះមុខរបរ | ខ្វះអណ្តូងទឹក | ០ | ង |
| | | | | | ខ្វះមុខរបរ | ៤ | ក |

៧- បន្ទាប់មកធ្វើការឯកភាពទៅលើបញ្ហាអាទិភាពទាំងនោះ។ បញ្ហាណាដែលមានពិន្ទុសរុបខ្ពស់ជាងគេ ត្រូវបានចាត់ទុកជាបញ្ហាអាទិភាពទី១ ។ ប្រសិនបើមានបញ្ហា ២ ឬ ៣ មានពិន្ទុសរុបដូចគ្នាត្រូវចាត់ ទុកថា

បញ្ហានេះមានអាទិភាពដូចគ្នា។ ធ្វើការបង្ហាញលទ្ធផលរបស់ក្រុមតូចទៅក្រុមធំ

៨- យកបញ្ហាអាទិភាពរបស់ក្រុមទាំងបីមកដាក់បញ្ចូលគ្នា ធ្វើការចាត់បញ្ហាដែលដូច ឬស្រដៀងគ្នានៅក្នុងក្រុមតែមួយ។

៩- ហើយរកបញ្ហាអាទិភាពសម្រាប់ភូមិទាំងមូលដោយប្រើការបោះឆ្នោតតាមតារាងខាងលើ។

❖ **ចំណុចគួរចងចាំៈ**

- ប្រសិនបើបញ្ហាដែលអ្នកចូលរួមបានលើកឡើងមានច្រើនអ្នកសម្របសម្រួលត្រូវចេះបញ្ចូលបញ្ហាដែលដូចគ្នាទៅក្នុងក្រុមតែមួយ ហើយពិនិត្យមើលបញ្ហាម្តងមួយៗព្រោះបញ្ហាខ្លះជាមូលហេតុនៃបញ្ហាចំបងណាមួយផ្សេងទៀត
- បើបញ្ចូលគ្នាហើយបញ្ហានៅតែមានចំនួនច្រើនអ្នកសម្របសម្រួលត្រូវធ្វើការឯកភាពជាមួយអ្នកចូល រួមម្តងសិនដោយកំណត់យកតែបញ្ហាសំខាន់ចំនួន ៥ សំរាប់បញ្ចូលក្នុងតារាងបោះឆ្នោតរកអាទិភាព
- អ្នកសម្របសម្រួលត្រូវរំលឹកដល់អ្នកចូលរួមថាក្នុងរយៈពេល១ ឆ្នាំយើងមិនអាចដោះស្រាយគ្រប់បញ្ហាបានទេ ដូច្នេះយើងត្រូវលើកយកបញ្ហាអាទិភាពមួយចំនួនដែលចាំបាច់ ហើយបន្ទាន់មកធ្វើការដោះស្រាយមុន
- ត្រូវពិចារណាលើគ្រប់គំនិតរបស់ក្រុមដែលបានលើកឡើងឱ្យបានស្មើៗគ្នា

❖ **ចំណុចគួរជៀសវាង**

- មិនត្រូវឱ្យមានគំនិតណាមួយលប់លើគំនិតអ្នកដទៃ
- កុំផ្តោតតែទៅលើអាទិភាពរបស់ក្រុមដែលមានសមាជិកច្រើន
- មិនត្រូវបញ្ចូលនូវគំនិតរបស់អ្នកសម្របសម្រួលទេ
- កុំប្រើសំណួរលោតចុះ លោតឡើង
- មិនត្រូវសម្តែងនូវការបដិសេធនៅចំពោះមុខ

## ២.២.៦ ការវិភាគដើមឈើបញ្ហា

❖ **គោលបំណង**

ការវិភាគដើមឈើបញ្ហាធ្វើឡើងក្នុងគោលបំណងៈ

- ដើម្បីជួយសមាជិកសហគមន៍ ស្ថាប័នអភិវឌ្ឍ អ្នកធ្វើផែនការ និងអ្នកស្រាវជ្រាវនានាធ្វើការកំណត់ពី មូលហេតុ និងផលប៉ះពាល់នៃបញ្ហាអាទិភាព
- ដើម្បីបង្កើននូវការវិភាគបញ្ហាមួយ ដោយជំរុញឱ្យមានការពិភាក្សាយ៉ាងផុលផុសពីមូលហេតុ និងផលប៉ះពាល់នៃបញ្ហា។

❖ **ដំណើរការក្នុងការអនុវត្ត**

១- បង្ហាញពីគោលបំណងដល់អ្នកចូលរួម

២- លើកយកបញ្ហាមួយមកធ្វើជាឧទាហរណ៍ឱ្យអ្នកចូលរួមមើល

**ឧទាហរណ៍**
**បញ្ហា:** ដីខ្សោះជីជាតិ
**មូលហេតុ:** ប្រើប្រាស់ជីគីមី និង ថ្នាំគីមីមិនសមស្រប មិនបានប្រើជីធម្មជាតិ
**ផលប៉ះពាល់:** ទិន្នផលទាប បាត់បង់ប្រាក់ចំណូល ចំណាកស្រុក ជីវភាពគ្រួសារធ្លាក់ចុះ

៣- ប្រាប់ឱ្យអ្នកចូលរួមយកបញ្ហាម្តងមួយៗមកគិតរកមូលហេតុ និងផលប៉ះពាល់។ គូសដើមឈើធំមួយលើក្រដាសផ្ទាំងធំ។ មិនត្រូវគូរមែក ឬឫសមុនទេ។ សរសេរបញ្ហាមួយនៅលើដើមឈើនោះ។

៤- បំផុសគំនិតជាមួយអ្នកចូលរួម លើមូលហេតុនានាដែលនាំអោយកើតមានបញ្ហាដោយដាក់សំណួរថា "*ហេតុអ្វី?*"។ គូស ឫសមួយសម្រាប់មូលហេតុមួយ និងសរសេរមូលហេតុនេះនៅលើឫសនោះ។

៥- សួរសំណួរបន្ត "*ហេតុអ្វី?*" ចំពោះមូលហេតុនីមួយៗដែលបានកំណត់រួចហើយ បន្តធ្វើការកំណត់ មូលហេតុបន្ទាប់បន្សំជាច្រើនទៀត។ សរសេរមូលហេតុបន្ទាប់បន្សំនេះ ចុះក្រោមតាមឫសនៅពី ក្រោមមូលហេតុសំខាន់ៗដែលគេបានកំណត់រួចហើយ។

៦- អនុញ្ញាតឱ្យអ្នកចូលរួមបន្តរហូតដល់គេអាចកំណត់លើមូលហេតុទាំងអស់។

៧- បន្ទាប់មកស្នើឱ្យអ្នកចូលរួមកំណត់ផលប៉ះពាល់ដែលកើតចេញពីបញ្ហានោះដោយដាក់សំណួរថា "*តើមានអ្វីកើតឡើង?*"។ គូរមែកមួយសម្រាប់ផលប៉ះពាល់មួយ

៨- ចូរសួរសំណួរដដែលឡើងវិញ "*តើមានអ្វីកើតឡើង?*" ចំពោះផលប៉ះពាល់នីមួយៗដែលបានកំណត់ ហើយនោះ ដើម្បីបង្ហាញពីផលប៉ះពាល់បន្ទាប់បន្សំនានា។ ចូរដាក់ផលប៉ះពាល់បន្ទាប់បន្សំទាំងនោះ តាមថ្នាក់ឡើងនៃមែកនៅខាងលើផលប៉ះពាល់សំខាន់ៗនានា។

៩- អនុញ្ញាតឱ្យអ្នកចូលរួមបន្តកំណត់លើផលប៉ះពាល់របស់បញ្ហានេះចប់សព្វគ្រប់ទាំងអស់។

❖ **ចំណុចគួរចងចាំ**

- ត្រូវលើកយកបញ្ហាណាមួយជាក់លាក់មកធ្វើការវិភាគ
- នៅពេលចាបផ្តើមធ្វើការវិភាគគួរកំណត់យកមូលហេតុសំខាន់ៗជាគោល

❖ **ចំណុចគួរជៀសវាង**

- មិនត្រូវបញ្ចូលនូវគំនិតរបស់អ្នកសម្របសម្រួលទេ
- កុំប្រើសំណួរលោតចុះ លោតឡើង និង មិនត្រូវសម្តែងនូវការបដិសេធនៅចំពោះមុខ
- មិនត្រូវឱ្យមានគំនិតណាមួយលប់លើគំនិតអ្នកដទៃ។




**ឧទាហរណ៍ដើមឈើបញ្ហា**

## ២.២.៧ ការស្វែងយល់ពីទស្សនវិស័យ

❖ **គោលបំណង**

បង្ហាញពីគោលគំនិតដែលសគហមន៍បានយល់ឃើញផ្សេងៗគ្នាសម្រាប់ថ្ងៃអនាគត។

❖ **ដំណើរការក្នុងការអនុវត្ត**

បង្ហាញពីគោលបំណងដល់អ្នកចូលរួម

១- នៅក្នុងក្រុមធំអ្នកសម្របសម្រួលធ្វើការបង្ហាញដល់អ្នកចូលរួមនូវបញ្ហាអាទិភាព និងមូលហេតុ និង ផលប៉ះពាល់នៃបញ្ហាដែលបានរកឃើញនូវជំហានមុន

២- អ្នកសម្របសម្រួលធ្វើការបំផុសគំនិតជាមួយអ្នកចូលរួមដោយប្រើនូវសំណួរដូចខាងក្រោមៈ ក្នុងរយៈពេល ១ ឆ្នាំខាងមុខ តើអ្នកចងឃើញស្ថានភាពនៅក្នុងសហគមន៍របស់អ្នកយ៉ាងដូចម្តេច?

៣- អ្នកសម្របសម្រួលសរសេរចម្លើយទាំងអស់ដាក់លើក្រដាសផ្ទាំងធំ

៤- ក្រោយពេលដែលអ្នកចូលរួមបានចូលរួមគំនិត ហើយអ្នកសម្របសម្រួលត្រូវធ្វើការចាត់ទស្សនវិស័យ ដែលដូច ឬស្រដៀងគ្នានៅក្នុងក្រុមតែមួយ ឬដាក់នៅក្រោមទស្សនវិស័យធំមួយ

៥- បន្ទាប់មកធ្វើការផ្ទៀងផ្ទាត់ ថាតើចម្លើយរបស់អ្នកចូលរួមមានលក្ខណៈពេញលេញហើយឬនៅ រួចហើយធ្វើការសម្រេចរួមគ្នា។

❖ **ចំណុចគួរចងចាំ**

- ទស្សនៈទាំងអស់នេះសុទ្ធតែត្រឹមត្រូវ
- ទស្សនៈរបស់អ្នកចូលរួមគឺមានលក្ខណៈខុសៗគ្នា ហើយបើពួកគាត់មានគំនិតបន្ថែមទៀត គឺត្រូវ

កត់ចំណាំ

- អ្នកសម្របសម្រួលត្រូវសួរបញ្ជាក់បន្ថែមចំពោះទស្សនៈដែលបានលើកឡើងពុំមានភាពច្បាស់លាស់។

❖ **ចំណុចគួរជៀសវាង**

- មិនត្រូវឱ្យមានទស្សនៈវិស័យតូចៗច្រើននោះទេ
- មិនត្រូវបញ្ចូលនូវគំនិតរបស់អ្នកសម្របសម្រួល
- កុំប្រើសំណួរលោតចុះ លោតឡើង
- មិនត្រូវសម្តែងនូវការបដិសេធនៅចំពោះមុខ
- មិនត្រូវឱ្យមានគំនិតណាមួយលប់លើគំនិតអ្នកដទៃ។

## ២.២.៨ ការវិភាគពីតម្រូវការ

❖ **គោលបំណង**

ពិភាក្សាលើតម្រូវការអាទិភាពដែលជាគន្លឹះសម្រាប់ដោះស្រាយនូវបញ្ហាអាទិភាព និងអាចសម្រេចបាននូវទស្សនវិស័យរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

❖ **ដំណើរការក្នុងការអនុវត្ត**

១- បង្ហាញពីគោលបំណងដល់អ្នកចូលរួម

២- អ្នកសម្របសម្រួលត្រូវបង្ហាញដល់អ្នកចូលរួមនូវបញ្ហាអាទិភាព និងទស្សនវិស័យដែលបានរកឃើញពីជំហានមុន

៣- អ្នកសម្របសម្រួលពន្យល់អំពីដំណើរការពិភាក្សា ដល់ក្រុមធំដែលមានគំរូ ដូចខាងក្រោម ៖




៤- បែងចែកអ្នកចូលរួមជាបីក្រុម គឺ ក្រុមស្ត្រី ក្រុមបុរស និងក្រុមងាយរងគ្រោះ ហើយក្រុមនីមួយៗត្រូវអនុវត្តតាមជំហានខាងក្រោម (ពីជំហាន ៥-៩)៖

៥- អ្នកសម្របសម្រួលធ្វើការបំផុសគំនិតជាមួយអ្នកចូលរួមដោយសួរនូវសំណួរដូចខាងក្រោម៖ តើមានតម្រូវការអ្វីខ្លះ ដើម្បីដោះស្រាយនូវបញ្ហាដែលបានរកឃើញ និងជួយឱ្យសម្រេចនូវទស្សនវិស័យរបស់អ្នក?

១- អ្នកសម្របសម្រួលសរសេរចម្លើយទាំងអស់ដាក់លើក្រដាសផ្ទាំងធំ

២- ក្រោយពេលដែលអ្នកចូលរួមបានចូលរួមគំនិតរួចហើយអ្នកសម្របសម្រួលត្រូវបញ្ចូលតម្រូវការ

ដែលដូចគ្នា ស្រដៀងគ្នា និងខុសគ្នាជាក្រុម

៣- ធ្វើការបូកសរុបនូវប្រភេទនៃតម្រូវការ ត្រូវកំណត់យកតែតំរូវការចំបងៗដើម្បីបញ្ចូលតារាងចាត់អាទិភាព

៤- អ្នកសម្របសម្រួល និងអ្នកចូលរួមធ្វើការចាត់អាទិភាពតម្រូវការដែលបានរកឃើញដោយអនុវត្តតាមតារាងខាងក្រោមៈ

| ឧបករណ៍ល្បាត | បច្ចេកទេសដាំដំណាំ | ទទួលផ្លូវថ្មី | អណ្តូងទឹក | មុខរបរបន្ថែម | | ពិន្ទុ | លំដាប់ថ្នាក់ |
|---|---|---|---|---|---|---|---|
| | ឧបករណ៍ល្បាត | ឧបករណ៍ល្បាត | ឧបករណ៍ល្បាត | មុខរបរបន្ថែម | ឧបករណ៍ល្បាត | ៣ | ខ |
| | | បច្ចេកទេសដាំដំ ណាំ | បច្ចេកទេសដាំដំណាំ | មុខរបរបន្ថែម | បច្ចេកទេសដាំដំណាំ | ២ | គ |
| | | | ទទួលផ្លូវថ្មី | មុខរបរបន្ថែម | ទទួលផ្លូវថ្មី | ១ | ឃ |
| | | | | មុខរបរបន្ថែម | អណ្តូងទឹក | ០ | ង |
| | | | | | មុខរបរបន្ថែម | ៤ | ក |

៥- ធ្វើការបង្ហាញលទ្ធផលរបស់ក្រុមតូចទៅក្រុមធំ

៦- ពិភាក្សាពេញអង្គ ដោយយកតម្រូវការរបស់ក្រុមទាំងបីមកដាក់បញ្ចូលគ្នាហើយរកតម្រូវការ អាទិភាពសម្រាប់ភូមិទាំងមូលដោយប្រើតារាងខាងលើ។

❖ **ចំណុចគួរចងចាំ**

- ការបញ្ជាក់នូវចម្លើយទាំងអស់នេះ គឺមានសារៈសំខាន់ណាស់ និងត្រូវការពេលវេលាគ្រប់គ្រាន់ក្នុងការពិភាក្សា ។
- អ្នកសម្របសម្រួលត្រូវចាំថាបញ្ហាមួយអាចមានតំរូវការច្រើន ឬមានតែមួយ

ឧទាហរណ៍ (១) បញ្ហាប្រជាជនឈឺច្រើន នោះតំរូវការ គឺមណ្ឌលសុខភាព ចំណេះដឹងពីការថែរក្សាសុខភាព ទឹកស្អាត បង្គន់អនាម័យ...

ឧទាហរណ៍ (២)បញ្ហាខ្វះផ្លូវថ្នល់ នោះតំរូវការ គឺផ្លូវថ្នល់

- ត្រូវពិចារណាអោយបានស្មើគ្នានូវតម្រូវការរបស់ក្រុមទាំងអស់

❖ **ចំណុចគួរជៀសវាង**

- មិនត្រូវមានទំនោរទៅលើែតតម្រូវការរបស់ក្រុមដែលមានសមាជិកច្រើនចូលរួម
- មិនត្រូវបញ្ចូលនូវគំនិតរបស់អ្នកសម្របសម្រួល
- កុំប្រើសំណួរលោតចុះ លោតឡើង
- មិនត្រូវសម្តែងនូវការបដិសេធនៅចំពោះមុខ
- មិនត្រូវឱ្យមានគំនិតណាមួយលប់លើគំនិតអ្នកដ៏ទៃ។

## ២.២.៩ វិភាគឧបសគ្គ និងដំណោះស្រាយលើតម្រូវការ

❖ **គោលបំណង**

- ដើម្បីស្វែងរកឧបសគ្គដែលធ្វើអោយតម្រូវការរបស់ ក្រុមស្ត្រី បុរស និងក្រុមងាយរងគ្រោះមិនអាចសម្រេចបាន
- ស្វែងរកដំណោះស្រាយទៅលើឧបសគ្គទាំងនោះ

❖ **ដំណើរការអនុវត្ត**

១- បង្ហាញពីគោលបំណងដល់អ្នកចូលរួម

២- អ្នកសម្របសម្រួលត្រូវបង្ហាញនូវតម្រូវការដែលបានរកឃើញពីជំហានមុនដល់អ្នកចូលរួម

៣- ពិភាក្សាពេញអង្គអ្នកសម្របសម្រួលបំផុសគំនិតជាមួយមួយអ្នកចូលរួមដោយសួរសំណួរថា ***តើមានឧបសគ្គអ្វីខ្លះដែលធ្វើឱ្យតម្រូវការមិនអាចសម្រេចបាន? តើមានដំណោះស្រាយអ្វីខ្លះសម្រាប់ឧបសគ្គទាំងនោះ?***

៤- ដោយលើកយកតម្រូវការម្តងមួយៗមកធ្វើការពិភាក្សាពេញអង្គ ដើម្បីរកឧបសគ្គ និងដំណោះស្រាយ

៥- អ្នកសម្របសម្រួលសរសេរនូវឧបសគ្គ និងដំណោះស្រាយដែលអ្នកចូលរួមបានលើកឡើងដាក់ក្រដាសផ្ទាំងធំ

៦- សង្ខេប និងបញ្ជាក់នូវចម្លើយទាំងនោះជាមួយអ្នកចូលរួម

❖ **ចំណុចគួរចងចាំ**

- លើកទឹកចិត្តឱ្យមានការចូលរួមពេញលេញពីអ្នកចូលរួម
- ការបញ្ជាក់ចម្លើយឡើងវិញជាមួយអ្នកចូលរួម គឺសំខាន់ដើម្បីរំឭកដល់ពួកគាត់
- ត្រូវពិចារណាលើគ្រប់ឧបសគ្គ និងដំណោះស្រាយរបស់អ្នកចូលរួមទាំងអស់

❖ **ចំណុចគួរជៀសវាង**

- មិនត្រូវបញ្ចូលគំនិតរបស់អ្នកសម្របសម្រួល
- មិនត្រូវប្រើសំណួរលោតចុះ លោតឡើង
- មិនត្រូវឱ្យមានគំនិតណាមួយលប់លើគំនិតអ្នកដទៃ។

## ឧទាហរណ៍: លទ្ធផលសរុបនៃពត៌មានដែលទទួលបាន

| បញ្ហា | ទីតាំងបញ្ហា | មូលហេតុនៃបញ្ហា | តម្រូវការ | ឧបសគ្គ | ដំណោះស្រាយ | យោបល់ជនជាតិ ដើមភាគតិច |
|---|---|---|---|---|---|---|
| ប្រជាពលរដ្ឋឈឺច្រើន | • ភូមិ ក<br>• ភូមិ ខ<br>• ឬភូមិទាំង២ | • ប្រជាពលរដ្ឋមានចំណេះដឹងទាប<br>• គ្មានមណ្ឌលសុខភាព<br>• គ្មានសេវាសុខភាព<br>• ខ្វះអនាម័យ<br>• ខ្វះការយល់ដឹងពីអនាម័យ | • ចង់ចេះអំពីរបៀបថែទាំសុខភាព | • ប្រជាពលរដ្ឋ ពិសេសស្ត្រី មិនសូវចេះអក្សរ | • អប់រំ និងផ្សព្វ ផ្សាយអំពីការ ថែទាំសុខភាព | • លើកទឹកចិត្តឱ្យចូលរួមដោះស្រាយបញ្ហា<br>• ចុះផ្សព្វផ្សាយទៅដល់ជនជាតិដើមភាគតិចត្រូវមានអ្នកបកប្រែ |
| | | | • មណ្ឌលសុខភាព | • ចំនួនប្រជាពលរដ្ឋ មិនគ្រប់តាមចំនួនដែលក្រសួងសុខា ភិបាលកំណត់ | • សាងសង់ប៉ុស្តិ៍សុខភាព និងផ្តល់សេវាកម្មសុខភាព | |
| | | | • សេវាសុខភាពតាមភូមិ | • ភ្នាក់ងារសុខភាពខ្វះសម្ភារបរិក្ខាពេទ្យ | • ពង្រឹងសមត្ថភាពបន្ថែម និងឧបត្ថម្ភសម្ភារពេទ្យ | |
| ផលត្រីថយចុះ | • ភូមិ ក<br>• ភូមិ ខ<br>• ភូមិគ | • ការនេសាទខុសច្បាប់<br>• កំណើនប្រជាពលរដ្ឋ<br>• បាត់បង់ជម្រកសត្វ | • ពង្រឹងសមត្ថភាពសហគមន៍នេសាទ | • ចំណេះដឹងរបស់គណៈកម្មការនៅមានកម្រិត | • ផ្តល់វគ្គបណ្តុះបណ្តាលដែលទាក់ទងលើការគ្រប់គ្រងធនធានធម្មជាតិ | • បង្រៀនពីបច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ<br>• ជាផ្នែកគាំទ្រដល់ការជីវភាពប្រចាំថ្ងៃដែរ |
| | | | • ផ្តល់ទុន និងបច្ចេក ទេសចិញ្ចឹមត្រី | • ប្រជាពលរដ្ឋមួយចំនួនមិនចេះអក្សរ | • ផ្តល់ពូជត្រី<br>• ជីកស្រះចិញ្ចឹមត្រី | |
| | | | • គោរពច្បាប់ជលផល | • ជីវភាពប្រជាជនខ្វះខាតខ្លាំងពេក | • ផ្សព្វផ្សាយការប្រើ ឧបករណ៍នេសាទ ត្រីជាលក្ខណៈ ប្រពៃណី | |

# ផ្នែកទី៣ នីតិវិធីនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

យើងអាចធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ក្នុងរូបភាពផ្សេងៗគ្នាជាច្រើន ហើយវិធីសាស្ត្រ និងបច្ចេកទេសដែលប្រើប្រាស់សម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺអាស្រ័យទៅលើះ

- អ្វីដែលយើងចង់ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- ធនធានដែលមានសម្រាប់ការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ(លុយ មនុស្ស មធ្យោបាយធ្វើដំណើរ)
- បទពិសោធន៍ផ្ទាល់ខ្លួនរបស់យើង លើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ជាទូទៅត្រូវបានរៀបចំឡើង តាមលំដាប់លំដោយចំនួន៤ជំហាន ដូចខាងក្រោមះ

១- ការត្រៀមរៀបចំ

២- ការប្រមូលព័ត៌មាន

៣- ការវិភាគព័ត៌មាន និង

៤- ការប្រើប្រាស់សេចក្ដីសន្និដ្ឋាន

*<u>ឧទាហរណ៍</u>*

**ការត្រៀមរៀបចំ ៖** ក្រុមប្រឹក្សាបានសម្រេចចិត្តធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការងារគ្រប់គ្រង និងអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។ សូចនាករមួយដែលអាចបញ្ជាក់ពីគោលបំណងនេះគឺថាតើប្រជាពលរដ្ឋមូលដ្ឋានបានចូលរួមប្រជុំនៅថ្នាក់ភូមិ ឬ ថ្នាក់ឃុំដែរឬទេ។ បន្ទាប់ពីការពិភាក្សា ក្រុមប្រឹក្សា ឃុំ សង្កាត់បានសម្រេចចិត្ត ប្រមូលព័ត៌មានស្ដីពីចំនួនបុរស និងស្ត្រី ដែលបានចូលរួមក្នុងការប្រជុំ ចំនួនពួកគេដែលមានអាយុក្រោម ៣០ឆ្នាំ ភូមិដែលពួកគេ រស់នៅ និងចំនួនប្រជាពលរដ្ឋក្រីក្រ ដែលបានចូលរួមក្នុងការប្រជុំ ។

**ការប្រមូលព័ត៌មាន ៖** ក្រុមប្រឹក្សាឃុំ សង្កាត់បានសម្រេចចិត្តសូមឱ្យគ្រូបង្រៀនបឋមសិក្សាជួយប្រមូលព័ត៌មានទាំងនេះ។ គ្រូបង្រៀនរូបនោះ បានរៀបចំជាទម្រង់មួយ សម្រប់កត់ត្រាពីចំនួនស្ត្រី និងបុរសដែលបានចូលរួមប្រជុំ អាយុ ភូមិដែលពួកគេរស់នៅ និងស្ថានភាពជីវភាពរស់នៅ (មាន-ក្រ) របស់ពួកគេ។ គ្រូបង្រៀនរូបនោះនឹងប្រមូលពត៌មាន ពីការចូលរួមរបស់ប្រជាពលរដ្ឋ មូលដ្ឋាននៅក្នុងការប្រជុំទៀងទាត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់រយៈពេល៦ខែ។

**១- ការវិភាគព័ត៌មាន ៖** ពិនិត្យលើពត៌មានដែលបានប្រមូល ក្រុមប្រឹក្សាឃុំយល់ឃើញថា មានបុរសមួយក្រុមតូចដែលមានអាយុច្រើនជាង៣០ឆ្នាំ និងដែលមានការយល់ដឹងច្រើន តែងតែបានចូលរួមប្រជុំ។ ពួកគេទាំងអស់សុទ្ធតែអញ្ជើញមកពីភូមិដែលនៅក្បែរនឹងសាលាឃុំ សង្កាត់។ តាមឯកសារស្តីពីប្រជាពលរដ្ឋបានបង្ហាញថា ក្នុងចំណោមភូមិទាំង៧នៃឃុំនេះ គឺមានចំនួនស្ត្រីច្រើនជាងបុរស ហើយឃុំនេះក្រជាងគេ។ ពត៌មានដែលប្រមូលបានមកនេះបង្ហាញ ថាមានមនុស្សតែមួយចំនួនតូចប៉ុណ្ណោះ ដែលបានចូលរួមក្នុង ការងារគ្រប់គ្រង និងអភិវឌ្ឍន៍របស់ឃុំ សង្កាត់ ហើយអ្នកទាំងនេះមិនមែនជាមនុស្សដែលក្រីក្រនោះទេ។

**២- សេចក្តីសន្និដ្ឋាន ៖** ក្រុមប្រឹក្សាឃុំអាចពិចារណាថា តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋជាពិសេសប្រជាពលរដ្ឋជាស្ត្រីភេទ ក្មេងៗ និងអ្នកក្រីក្រ ឱ្យចូលរួមប្រជុំដើម្បីធានាថា សេចក្តីសម្រេចដែលបានធ្វើឡើងនៅក្នុង ការប្រជុំនេះបានបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋមូលដ្ឋាន ។ វាហាក់បីដូចជាការលំបាកក្នុងការកៀងគរប្រជាពលរដ្ឋ មូលដ្ឋានឱ្យចូលរួមប្រជុំនេះ ឃុំ សង្កាត់គួរតែធ្វើយ៉ាងណា ដើម្បីផ្សព្វផ្សាយពត៌មានឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋមូលដ្ឋាន ។

## ៣.១ ការត្រៀមរៀបចំ

ជំហានដំបូងនេះ ជាជំហានសំខាន់ ព្រោះថាវាមានឥទ្ធិពលយ៉ាងខ្លាំង លើលទ្ធផលរបស់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃដែលយើងត្រូវធ្វើ។ បើសិនជាយើងមិនច្បាស់ពីអ្វីដែលត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ឱ្យបានជាក់លាក់ ឬមិនមានគំនិតល្អៗ អំពីវិធីសាស្ត្រក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទេយើងនឹងខ្ជះខ្ជាយ ពេលវេលាយ៉ាងច្រើន ដោយគ្មានលទ្ធផលគួរជាទីគាប់ចិត្តនៅចុងបញ្ចប់។

ការត្រៀមរៀបចំការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ គឺជាឱកាសដ៏ល្អមួយផងដែរដើម្បីធ្វើឱ្យមាន ការពិគ្រោះយោបល់។ ជនបង្គោលតាមដាន ត្រួតពិនត្យ និងវាយតម្លៃឃុំ សង្កាត់នឹងរៀបចំផែនការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ហើយបន្ទាប់មកដាក់ជូនមេឃុំ ចៅសង្កាត់ សម្រាប់ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានារបស់ឃុំ សង្កាត់ និងអនុម័ត ។

ដើម្បីធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃមួយ **<u>ជាពិសេស សម្រាប់ការវាយតម្លៃ</u>** គេត្រូវមានការរៀបចំផែនការយ៉ាងហ្មត់ចត់ជាមុន ដោយត្រូវអនុវត្តទៅតាម ៥ជំហានដូចខាងក្រោម៖

១- ការកំណត់គោលបំណង

២- ការកំណត់ ឬជ្រើសរើសសូចនាករ?

៣- ការកំណត់សំណួរគន្លឹះ

៤- ការកំណត់វិធីសាស្ត្រ និង

៥- ការរៀបចំផែនការសកម្មភាព

### ៣.១.១ ការកំណត់គោលបំណង

❖ តើត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើអ្វីខ្លះ?

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដែលឃុំ/សង្កាត់ ធ្វើឡើងត្រូវផ្តោតទៅលើការអនុវត្តផែនការអភិវឌ្ឍន៍ និងថវិកាប្រចាំឆ្នាំ ដើម្បីទទួលបានព័ត៌មានស្តីពីស្ថានភាពអភិវឌ្ឍន៍ទូទៅនៅក្នុងឃុំ/សង្កាត់។

អ្វីដែលត្រូវធ្វើឱ្យបានសម្រេចនៅក្នុងផ្នែកនេះ គឺពិភាក្សា និងព្រមព្រៀងគ្នាលើអ្វីខ្លះដែលជាចំណុចសំខាន់ជាក់លាក់នៃគម្រោងឃុំ សង្កាត់ ឬការផ្តល់សេវាកម្ម ដែលនឹងត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីទទួលបាននូវព័ត៌មានដែលយើងចង់បាន។ មូលដ្ឋានក្នុងការសម្រេចថាអ្វីខ្លះដែលត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺពិនិត្យមើលទៅលើគោលបំណង និងរបៀបរបបនៃការអនុវត្តគម្រោង និងការផ្តល់សេវាកម្ម។

**❖ ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធ**

យើងអាចប្រមូលបានព័ត៌មានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមួយចំនួនចេញពី ទម្រង់ព័ត៌មានគម្រោង និងទម្រង់ព័ត៌មានបច្ចេកទេស (ដូចជា គម្រោងអណ្តូងទឹក ផ្លូវ សាលារៀន និងគម្រោងធារាសាស្ត្រ)។ យើងអាចរកទម្រង់ទាំងនេះបាននៅក្នុងសៀវភៅណែនាំស្តីពីការ អនុវត្តគម្រោងដែលប្រើប្រាស់ មូលនិធិឃុំ/សង្កាត់។

ផែនការការងាររបស់អ្នកទទួលការ គឺជាប្រភពព័ត៌មានដ៏សំខាន់មួយទៀត ស្តីពីការតាមដាន ត្រួតពិនិត្យលើធនធាន សកម្មភាព លទ្ធផលរបស់គម្រោងមួយដែលអនុវត្តដោយអ្នកទទួលការ។ ផែនការសកម្មភាពនេះនឹងបង្ហាញពីសកម្មភាពដែលត្រូវអនុវត្ត ពេលចាប់ផ្តើម និងបញ្ចប់សកម្មភាពនីមួយៗ។

❖ **ចំពោះគម្រោងដែលមិនមែនជាហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពផ្តល់សេវាកម្ម**

ដូចជាការផ្តល់ធនធាន សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សកម្មភាពបណ្តុះបណ្តាល ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ ឬកម្មវិធីវិនិយោគឃុំ/សង្កាត់)អាចផ្តល់ព័ត៌មានជាមូលដ្ឋាន ថាតើគម្រោងធ្វើទៅលើអ្វី ហេតុអ្វី នៅកន្លែងណា នៅពេលណា និងថាតើគម្រោងត្រូវអនុវត្តយ៉ាងដូចម្តេច ដោយមានចំណាយប៉ុន្មាន ហើយមានស្ត្រី និងបុរសប៉ុន្មាននាក់ ដែលជាអ្នកទទួលផល។

បើសិនព័ត៌មានខាងលើនេះមិនមាននៅក្នុងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងផែនការថវិកាប្រចាំឆ្នាំរបស់ឃុំ/សង្កាត់ទេនោះចាំបាច់ត្រូវតែគូសបញ្ជាក់ឱ្យបានច្បាស់ថា តើត្រូវរៀបចំធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅពេលណា កន្លែងណា... ។ល។

❖ **ហិរញ្ញវត្ថុ និងពេលវេលាសមស្របសម្រាប់ការតាមដានត្រួត ពិនិត្យ និងវាយតម្លៃ**

នៅពេលដែលយើងពិចារណាពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ យើងគួរតែគិតផងដែរពីការចំណាយលើការងារនេះ។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺទាមទារឱ្យមានពេលវេលា និងប្រាក់កាសសមស្រប។ អ្នកដែលធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវចំណាយពេលវេលារបស់ខ្លួន ដើម្បីបំពេញការងារនេះ ហើយបើសិនជាគេជួបជាមួយអ្នកដទៃនៅពេលធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ អ្នកទាំង អស់នោះ ក៏ចំណាយពេលដូចគ្នា។ ក្នុងការអនុវត្តសកម្មភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គួរមានការចំណាយផ្សេងៗ ដូចជា ថ្លៃធ្វើដំណើរ ប៊ិច ក្រដាស ថតរូប និងអាហារសម្រន់ (បើសិនជាចាំបាច់) ។

### ៣.១.២ ការកំណត់ ឬជ្រើសរើសសូចនាករ

នៅពេលដែលយើងយល់ច្បាស់ពីអ្វីដែលត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃហើយនោះ ដំណាក់កាលបន្ទាប់មកទៀត យើងត្រូវកំណត់ថាតើព័ត៌មានអ្វីខ្លះដែលយើងត្រូវការ។ ព័ត៌មានទាំងនោះហៅថា ***<u>សូចនាករ</u>*** សូចនាករ គឺជាព័ត៌មានសំខាន់ៗ ដែលជួយឱ្យយើង៖

- ❖ *វាស់វែងសមិទ្ធផល*
- ❖ *ឆ្លុះបញ្ចាំងបម្រែបម្រួល និង*
- ❖ *វាស់ស្ទង់គុណភាពការងារដែលបានអនុវត្ត*

លើសពីនេះទៅទៀត សូចនាករ គឺជាព័ត៌មានដែលអាចឱ្យយើងសន្និដ្ឋានបានពីអ្វីមួយ។ ឧទាហរណ៍យើងឃើញមេឃមានពពកអាប់អួរច្រើន ក្តៅស្អុះ និងមានសត្វស្រមោចជាច្រើនចេញពីរន្ធ នោះយើងអាចសន្និដ្ឋានបានថា ថ្ងៃនេះមេឃនឹងភ្លៀង។ សូចនាករ (ក្តៅស្អុះ ពពកអាប់អួរ មានស្រមោចច្រើនចេញពីរន្ធ) បានធ្វើឱ្យយើងអាចសន្និដ្ឋានថា មេឃប្រហែលជានឹងភ្លៀង ។ យើងអាចកំណត់ចំនួនសូចនាករច្រើន ឬតិច គឺអាស្រ័យទៅតាមខ្លឹមសារនៃគោលបំណងរបស់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដែលយើងបានកំណត់។ បើសិនជាគោលបំណងនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទូលំទូលាយ នោះសូចនាករក៏ត្រូវមានច្រើនដែរ តែបើសិនជាគោលបំណងតូច នោះសូចនាករក៏ត្រូវតិចតួចទៅតាមនោះដែរ ។ ជាទូទៅសូចនាករមាន២ប្រភេទគឺ៖

***<u>សូចនាករបរិមាណ:</u>*** ជាសូចនាករដែលយើងអាចរាប់បាន ដូចជា ចំនួនឡានដឹកគ្រោះក្របាម ដើម្បី ជួសជុលផ្លូវ ឬចំនួនប្រជាពលរដ្ឋ ដែលប្រើប្រាស់ទឹកអណ្តូង) ។ល។

***សូចនាករគុណភាព:*** ជាសូចនាករដែលយើងមិនអាចរាប់បាន ដូចជា ការពេញចិត្តរបស់អ្នកប្រើប្រាស់ ផ្លូវដែលទើបជួសជុលរួច ឬ គុណភាពទឹកដែលយកពីអណ្តូង)។ល។

សូចនាករសម្រាប់តាមដានត្រួតពិនិត្យធនធាន លទ្ធផល និងផលប៉ះពាល់ អាចជាសូចនាករបរិមាណ ឬ ជា សូចនាករគុណភាព។

សូចនាករមួយដែលល្អ អាស្រ័យទៅលើប្រភេទនៃសកម្មភាពដែលបាននឹងកំពុងអនុវត្ត ។ តារាងខាងក្រោមនេះ នឹងបង្ហាញឱ្យឃើញពីសូចនាករធនធាន លទ្ធផល និងសូចនាករផលប៉ះពាល់របស់គម្រោងមួយចំនួនដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

| គម្រោង | សូចនាករធនធាន | សូចនាករលទ្ធផល | សូចនាករផលប៉ះពាល់ |
|---|---|---|---|
| គម្រេងាជួសជុលផ្លូវ | ▪ ចំនួនឡានដឹកគ្រួសក្រហម | ▪ ប្រវែងផ្លូវដែលបានជួសជុល<br>▪ ប្រវែងផ្លូវដែលត្រូវជួសជុលក្រោយ ពីរដូវភ្លៀង (សូចនាករគុណភាព) | ▪ ចំណាយលើការធ្វើដំណើរដោយ រថយន្តឈ្នួល<br>▪ តម្លៃកសិផល |
| គម្រេងាសាងសង់ អណ្តូង | ▪ ពេលវេលាសម្រាប់ជីកអណ្តូង | ▪ ជម្រៅអណ្តូង<br>▪ បរិមាណទឹកដែលអាចយក ប្រចាំថ្ងៃ | ▪ ពេលវេលាដែលស្ត្រីត្រូវយកទឹកប្រចាំថ្ងៃ<br>▪ ការផ្លាស់ប្តូរឥរិយាបថប្រើប្រាស់ទឹក |
| គ្រឿងសង្ហារឹមសម្រាប់សាលារៀន | ▪ បរិមាណទុនបដិភាគរបស់ប្រជាពលរដ្ឋមូលដ្ឋាន | ▪ ចំនួន និងគុណភាពសង្ហារឹមដែលបានទិញ | ▪ អត្រាចូលរៀនរបស់កុមារ<br>▪ ចំនួនកុមារដែលបន្តការសិក្សាក្រោយបឋមសិក្សា |
| វគ្គបណ្តុះបណ្តាល វិជ្ជាជីវៈ | ▪ ចំនួននិងរយៈពេលនៃវគ្គ បណ្តុះបណ្តាល | ▪ ចំនួនអ្នចូលរួមដែលបានបញ្ចប់ការសិក្សា ហើយទទួលបានសញ្ញាបត្រ | ▪ ចំនួនអ្នកចូលរួមដែលបានបង្កើត អាជីវកម្មខ្លួនឯងដោយប្រើប្រាស់ ជំនាញដែលបានរៀន |
| ថ្នាក់អក្ខរកម្ម | ▪ ចំនួនថ្នាក់អក្ខរកម្ម | ▪ ចំនួនបុរសស្ត្រីដែលអាចអានក្តាខៀនព័ត៌មានរបស់ឃុំនៅចុងឆ្នាំ | ▪ ចំនួនបុរសស្ត្រីដែលអាចអាន និងយល់លិខិតប័ណ្ណផ្សព្វផ្សាយ កសិកម្ម និងសុខភាពបាន |

### ៣.១.៣ ការកំណត់សំណួរគន្លឹះ

នៅពេលដែលយើងបានជ្រើសរើសសូចនាកររួចហើយ យើងត្រូវកំណត់សំណួរគន្លឹះ ដែលត្រូវប្រើក្នុងការប្រមូលព័ត៌មាន សម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ។ សំណួរគន្លឹះទាំងនោះ ភាគច្រើនចាប់ផ្តើមឡើងដូចខាងក្រោមនេះ ៖

- តើគម្រោងសម្រេចបានលទ្ធផល**អ្វីខ្លះ**? តើលទ្ធផលទាំងនោះ ស្របទៅនឹងការសង្ឃឹមទុកដែរឬទេ?
- **ហេតុអ្វី**បានជាសកម្មភាព ឬគម្រោងនោះ មានសារៈសំខាន់ចំពោះឃុំ/សង្កាត់?
- **តើកន្លែងណា** (ភូមិអ្វី) ដែលសកម្មភាព ឬ គម្រោងបានត្រូវអនុវត្ត ហើយហេតុអ្វីបានជាអនុវត្ត នៅភូមិនោះហើយភូមិឯទៀតមិនមាន?
- **តើនៅពេលណា** ដែលសកម្មភាព ឬ គម្រោងត្រូវបានអនុវត្ត ?

- តើសកម្មភាព ឬគម្រោងត្រូវបានអនុវត្ត**យ៉ាងដូចម្តេច** ? តើនីតិវិធីអនុវត្តគម្រោងនេះ ទទួលបានលទ្ធផលល្អដែរឬទេ?
- តើសកម្មភាព ឬគម្រោងនោះ នឹង**ចំណាយអស់ប៉ុន្មាន**? តើការចំណាយនោះ សមស្របនឹងការគ្រោងទុក ដែរឬទេ? តើមានទុនចូលរួមផ្សេងទៀតដែរឬទេ?
- តើគោលបំណងរបស់គម្រោងសម្រេចបាន**កម្រិតណា** ?

**ឧទាហរណ៍ សំណួរខាងក្រោមនេះ សម្រាប់គម្រោងហេដ្ឋារចនាសម្ពន្ធ**

| | |
|---|---|
| **អ្វីខ្លះ?** | ការសាងសង់ផ្លូវគ្រួសក្រហមមួយខ្សែមាន៣គីឡូម៉ែត្រ មានលូកាត់ផ្លូវចំនួន៥ ក្នុងរយៈពេល២ឆ្នាំ ដូចនេះ នៅក្នុងភូមិទាំងអស់ក្នុង ឃុំខ្ពស់អាចធ្វើដំណើរបានពេញមួយឆ្នាំៗ។ អ្វីដែលត្រូវធ្វើការត្រួតពិនិត្យគឺថាតើការសាងសង់នេះពិតជាបាន៣គីឡូម៉ែត្រ និងស្រប តាមលក្ខខណ្ឌបច្ចេកទេសទាំងអស់ដែរឬទេ ។ |
| **ហេតុអ្វី?** | ប្រជាពលរដ្ឋមូលដ្ឋានអាចធ្វើដំណើរលើផ្លូវនេះបានយ៉ាងងាយស្រួល។ ការធ្វើដំណើរដោយមធ្យោបាយផ្សេងៗកាន់តែងាយស្រួលហើយមានតម្លៃថោកជាងមុន។ ក្រោយពេលផ្លូវសាងសង់រួចរាល់ យើងគួរពិនិត្យមើលថាតើថ្លៃធ្វើដំណើរពិតជាបានថោកជាងមុនឬហើយបើសិនជាមានការធ្វើដំណើរកាន់តែច្រើនឡើងមានន័យថាផ្លូវត្រូវបានកែលំអ។ |
| **នៅឯណា?** | យើងត្រូវធ្វើការពិនិត្យនៅលើផែនទី ដើម្បីឱ្យប្រាកដថាផ្លូវនេះត្រូវបានសាងសង់នៅកន្លែងដែលបានកំណត់។ តែបើ សិនជាគម្រោងនេះជាការជួសជុលផ្លូវចាស់ដែលមានស្រាប់នោះ ប្រាកដណាស់ផ្លូវដែលទើបជួសជុលរួច ពិតជានៅ នឹងកន្លែងដើមជាមិនខាន លើកលែងតែមានករណីមួយចំនួន ដូចជា ទឹកជំនន់ ឬការបាក់ដី ជាដើម ទើបអាចធ្វើឱ្យ ផ្លូវនោះត្រូវបានកាត់បន្ថយចម្ងាយ ។ល។ |
| **នៅពេលណា?** | តារាងព័ត៌មានគម្រោងមិនបានផ្តល់ព័ត៌មាននេះទេ។ យើងត្រូវប្រមូលពត៌មាននេះពីប្រភពផ្សេងៗទៀតដូចជា ផែនការ ការងាររបស់អ្នកទទួលការ។ អ្វីដែលយើងត្រូវដឹងគឺ តើគម្រោងនឹងចាប់ផ្តើមនៅពេលណា បញ្ចប់នៅ ពេលណា ហើយតើការសាងសង់នេះ មានរយៈពេលប៉ុន្មានថ្ងៃ ។ ជាក់ស្តែង គម្រោងនេះត្រូវចាប់ផ្តើមដំណើរការ សាងសង់នៅរដូវប្រាំង ដើម្បីទទួលបានគុណភាពខ្ពស់ ។ |
| **ដូចម្តេច?** | សម្រាប់គម្រោងសាងសង់ និងគម្រោងជួសជុលផ្លូវ កិច្ចសន្យាត្រូវបានធ្វើឡើងឱ្យអ្នកទទួលការធ្វើ។ ការតាមដាន ត្រួតពិនិត្យផ្នែក បច្ចេកទេសនឹងត្រូវធ្វើឡើងដោយមន្ត្រីគាំទ្របច្ចេកទេស ប៉ុន្តែមន្ត្រីនេះមិនអាចធ្វើការតាមដាន ត្រួតពិនិត្យ ដល់ទីកន្លែងឱ្យបានរាល់ថ្ងៃនោះទេ។ ដូចនេះ ក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវធ្វើការតាមដានត្រួតពិនិត្យផ្នែក បច្ចេកទេសខ្លះៗដែរ ដូចជាពិនិត្យមើលថា តើផ្លូវត្រូវបានសាងសង់តាមទំហំ និងបណ្តោយដែលបានកំណត់ ដែរឬទេ តើកម្រាស់គ្រោះក្រហមត្រឹមត្រូវដែរឬទេ និងតើជើងទេរផ្លូវត្រឹមត្រូវដែរឬទេ ។ |
| **តម្លៃប៉ុន្មាន?** | ផ្អែកលើទម្រង់ព័ត៌មានគម្រោង យើងឃើញថាគម្រោងនេះនឹងចំណាយអស់២០លានរៀល ក្នុងឆ្នាំ ២០០៣ ហើយ ២០លានរៀលទៀត នៅឆ្នាំ ២០០៤ ។ ការទូទាត់នឹងត្រូវធ្វើឡើងឱ្យអ្នកទទួលការ បន្ទាប់ពីមានការបញ្ជាក់ពីមន្ត្រី គាំទ្របច្ចេកទេស និងដែលមាន ការចុះហត្ថលេខារបស់មេឃុំ ចៅសង្កាត់ ។ |
| **អ្នកទទួលផលប៉ុន្មាននាក់?** | ផ្អែកលើទម្រង់ព័ត៌មានគម្រោង យើងឃើញថា គម្រោងនេះមានអ្នកទទួលផលសរុបចំនួន ២៧០០នាក់ ដែលក្នុង នោះមានស្ត្រីចំនួន ១៣៥១នាក់។ បន្ទាប់ពីគម្រោងបានបញ្ចប់ យើងគួរតែធ្វើការពិនិត្យមើលថាតើប្រជាពលរដ្ឋមូលដ្ឋានយល់ថាពួកគេពិតជាបាន ព្រយោជន៍ពីផ្លូវនោះដែរឬទេ ហើយតើពួកគេទទួលបានក្នុងកម្រិតណា។ ប្រាកដ ណាស់ យើងនឹងមិនចុះទៅសាកសួរមនុស្សទាំង ២៧០០នាក់ក្នុងឃុំនោះទេ។ |

### ៣.១.៤ ការកំណត់វិធីសាស្ត្រ

មានវិធីសាស្ត្រជាច្រើនសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ហើយវិធីសាស្ត្រខ្លះមានការលំបាក ឬចំណាយពេលវេលា និងធនធានច្រើនជាងវិធីសាស្ត្រឯទៀត ។ នៅក្នុងមេរៀននេះ យើងគ្រាន់តែលើកយក វិធីសាស្ត្រងាយៗមួយចំនួនតូចមកបញ្ជាក់ជូនតែប៉ុណ្ណោះ។

*ការសង្កេតពិនិត្យ*

នេះជាឧបករណ៍សាមញ្ញបំផុតសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។វិធីសាស្ត្រនេះគឺអ្នកដែលកំពុងធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃត្រូវសួរខ្លួនឯងថា៖

- តើខ្ញុំឃើញអ្វីខ្លះ?
- តើប្រជាពលរដ្ឋធ្វើអ្វីខ្លះ?
- តើសកម្មភាពគម្រោងកំពុងចាប់ផ្តើមឬទេ?
- តើវាបានអនុវត្តល្អ ដោយគ្មានកំហុស ឬវិបត្តអ្វីទេ?
- តើប្រជាពលរដ្ឋដែលគិតថានឹងទទួលបានផលប្រយោជន៍ បានប្រើប្រាស់អ្វីដែលបានសាងសង់ឡើង ឬក៏ប្រើជំនាញឬ ចំណេះដឹងថ្មីដែលពួកគេបានទទួលឬទេ?

*សម្ភាសន៍ផ្ទាល់ជាមួយមនុស្សសំខាន់ៗ*

*មនុស្សសំខាន់ គឺជាអ្នកដែលយល់ដឹងច្រើនជាងមនុស្សសាមញ្ញធម្មតា និងអាចពន្យល់បានអំពីអ្វីៗ កំពុងកើតឡើង ។ មនុស្សសំខាន់នៅទីនេះ មិនមានន័យដល់អ្នកមានទ្រព្យសម្បត្តិ ឬបុណ្យសក្តិខ្ពង់ខ្ពស់នោះ ទេ ។ ឧទាហរណ៍ៈ បើយើងចង់ដឹងពីការលំបាកនៅពេលស្រវឹងគ្រឿងញៀននោះ អ្នកដែលជក់គ្រឿងញៀនគឺ ជាមនុស្ស សំខាន់ ព្រោះពួកគេជាមនុស្សដែលបានជួបប្រទះនូវការលំបាកទាំងនោះដោយខ្លួនឯង។ ម៉្យាងទៀត បើយើងចង់ដឹង ពីរបៀបសម្រាលកូន គឺមានតែឆ្មបទេដែលអាចផ្តល់ចម្លើយត្រឹមត្រូវឱ្យយើងបានល្អជាងគេ ។*

*ការសម្ភាសន៍ ឬការពិភាក្សាជាក្រុម*

ជាធម្មតា ការពិភាក្សាក្រុមត្រូវចំណាយពេលប្រហែល១ ទៅ ២ម៉ោង លើប្រធានបទជាក់លាក់ណា មួយជាមួយមនុស្សមួយក្រុមតូច។ គុណសម្បត្តិមួយនៃការពិភាក្សាជាក្រុម គឺអាចទទួលបានគំនិតយោបល់អ្នក ទាំងនោះរហ័សជាងការសម្ភាសន៍ជាមួយពួកគេម្នាក់ម្តងៗ។ ការសម្ភាសន៍ ឬការពិភាក្សាជាក្រុមនេះអាចជំរុញ ឱ្យមានការផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ក្នុងចំណោមសមាជិកក្រុមពិភាក្សា ហើយយើងអាចទទួលបាន ព័ត៌មានច្រើន និងកាន់តែស៊ីជម្រៅ ។ អ្នកសម្របសម្រួលការពិភាក្សានេះ ជាធម្មតាត្រូវរៀបចំសំណួរគន្លឹះ មួយចំនួនសម្រាប់បំផុសឱ្យមានការពិភាក្សា និងលើកសំណួរដេញដោលសួរបន្ត ដើម្បីទទួលបានព័ត៌មានលំអិត និង កាន់តែស៊ីជម្រៅ ។

### ៣.១.៥ ការរៀបចំផែនការសកម្មភាព

រហូតដល់ពេលនេះ យើងបានដឹងពីព័ត៌មានដែលត្រូវប្រមូល វិធីសាស្ត្រប្រមូលព័ត៌មាន និងសំណួរសំខាន់ៗ ដែលយើងត្រូវសួរ។ ដូចនេះយើងត្រូវសម្រេចចិត្តថាតើត្រូវចាប់ផ្តើមសកម្មភាព/ការងារនៅពេលណា ហើយអ្នកណាធ្វើអ្វីខ្លះ។

ឧបករណ៍មួយដែលយើងអាចប្រើបាន និងដែលអាចអោយយើងបង្ហាញនូវរាល់ព័ត៌មានដែលពាក់ព័ន្ធ គឺ

តារាងម៉ាទ្រិកផែនការសកម្មភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ យើងអាចកែតម្រូវតារាងម៉ាទ្រិកផែនការសកម្មភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនេះ ដោយបន្ថែមកូឡោន ឬផ្លាស់ប្តូរទីតាំងកូឡោននីមួយៗ ក៏ទៅតាមតម្រូវការជាក់ស្តែង។ ខាងក្រោមនេះ គឺជាឧទាហរណ៍ បញ្ជាក់ពីការរៀបចំតារាងម៉ាទ្រិកផែនការសកម្មភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

តារាងម៉ាទ្រិកផែនការសកម្មភាពតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងកែលម្អផ្លូវ

| សូចនាករ | សំណួរគន្លឹះ | វិធីសាស្រ្ត | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ទីតាំងពិតប្រាកដរបស់ផ្លូវ | តើអ្នកទទួលការបានសាងសង់ផ្លូវ ទៅតាមទីកន្លែងដែលបានកំណត់ ដែរឬទេ? | ការសង្កេតពិនិត្យ | • ពេលចាប់ផ្តើមគម្រោង<br>• ក្រោយពេលចាក់គ្រឹះ | • មន្ត្រីគាំទ្របច្ចេកទេស (លោក **ក**)<br>• គណៈកម្មការគ្រប់គ្រងគម្រោង (លោក ខ លោក គ ..) |
| ទំហំផ្លូវ | តើផ្លូវមានបណ្តោយ ទទឹង និង កម្រាស់ផ្លូវ ត្រឹមត្រូវដែរឬទេ? | ការសង្កេតពិនិត្យ វាស់វែង | ២ដងក្នុង១សប្តាហ៍ ដោយចៃដន្យ | |
| លូបង្ហូរ | តើនៅសងខាងផ្លូវមានលូបង្ហូរ ដែរឬទេ? កម្ពស់និងទំហំ សមស្រប ដែរឬទេ? តើទឹកភ្លៀង អាចហូរ បានដោយស្រួលដែរឬទេ? | ការសង្កេតពិនិត្យ វាស់វែង | ការត្រួតពិនិត្យជាទូទៅមុនពេល អនុម័តបើកប្រាក់បន្ទាប់ពី ភ្លៀងខ្លាំង ចុះពិនិត្យថា តើលូបង្ហូរអាចទ្រាំទ្រដែរឬទេ? | |
| ពេលវេលា និងការចំណាយលើការធ្វើដំណើរ | ក្រោយពីផ្លូវត្រូវបានកែលម្អតើរយៈ ពេលនិងចំណាយលើការធ្វើដំណើរ ត្រូវបានកាត់បន្ថយដែរឬទេ? | ការអង្កេតលើអ្នកបើកតាកស៊ី ៥នាក់ដោយសួរថាតើត្រូវ ចំណាយពេលនិងតម្លៃ ប៉ុន្មាន សំរាប់ការធ្វើដំណើរម្តង? | រៀងរាល់៣ខែម្តង ក្រោយពី ផ្លូវបានសាងសង់បញ្ចប់ | ជបនង្គោលតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ឃុំ សង្កាត់ |
| ការធ្វើចរាចរណ៍លើផ្លូវ | តើមានការធ្វើចរាចរច្រើនជាងមុនឬ? តើការធ្វើចរាចរលើផ្លូវនេះ មានរូបភាពអ្វីខ្លះ? (ឡានធំៗ ..) | រាប់រទេះគោ កង់ ម៉ូតូ រថយន្ត និងរថយន្តធំៗ ។ | - ធ្វើម្តងមុនពេលគម្រោងផ្លូវ ចាប់ផ្តើម<br>- រៀងរាល់បីខែម្តង បន្ទាប់ពី គម្រោងផ្លូវបានបញ្ចប់ ។ | គណៈកម្មការគ្រប់គ្រងគម្រោង (លោក ខ លោក គ ..) |
| កំណើនសេវាកម្មក្នុងឃុំ | តើមានសេវាកម្មច្រើនជាងមុនដែលត្រូវបានបញ្ជូនទៅឃុំឬ? តើគុណភាពរបស់ វាល្អជាងមុនឬ? | ជាបន្ត | មេឃុំ ក្រុមប្រឹក្សា និងស្មៀន | |
| កំណើនប្រាក់ចំណូលរបស់កសិករ | តើប្រាក់ចំណូលរបស់កសិករកើនឡើង ឬ? បើសិនជាកើន តើវាកើនក្នុង | អង្កេតលើកសិករ១០នាក់ក្នុង ១ភូមិៗ ដើម្បីពិនិត្យមើលថា តើពួកគេលក់ | មួយខែ ក្រោយពី ប្រមូលផល | ជនបង្គោលតាមដានវាយតម្លៃ សមាជិក គ.ជ.ឋ |

| | | | | |
|---|---|---|---|---|
| | ចំណោមកសិករប្រភេទណា ហើយកើន បានប៉ុន្មាន? | ផលិតផល បាន ក្នុងតម្លៃប៉ុន្មាន។ | | |
| ការប្រើប្រាស់ផ្លូវ | តើផ្លូវនេះ អាចប្រើប្រាស់បានយូរ អង្វែងទេ? | រាប់រទេះគោ កង់ ម៉ូតូ រថយន្ត និងរថយន្តធំៗ ។ | រៀងរាល់បីខែម្តង បន្ទាប់ពី គំរោងផ្លូវបាន បញ្ចប់ ។ | គណៈកម្មការគ្រប់គ្រង គម្រោង (លោក ខ លោក គ ..) |
| តម្រូវការថែទាំ និង ជួសជុល ផ្លូវ | តើមានផ្នែកណាខ្លះនៃផ្លូវ ដែលត្រូវ ជួសជុល?- បើសិនជាមាន នៅកន្លែងណា ចំណាយប៉ុន្មាន ហើយត្រូវ ជួសជុលអ្វីខ្លះ? | ធ្វើការអង្កេតលើផ្នែក ដែលខូតខាត ដោយរាប់ ប៉ុន្មាន កន្លែង និងត្រូវ ជួសជុល កម្រិតណា? | ពិនិត្យជារៀងរាល់ខែ | គណៈកម្មការគ្រប់ គ្រងគម្រោង (លោក ខ លោក គ ..) |

## ៣.២ ការប្រមូលព័ត៌មាន

### ៣.២.១ ប្រភពនៃព័ត៌មាន

ដើម្បីធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ យើងត្រូវការព័ត៌មានជាមូលដ្ឋាន ។ មុនចាប់ផ្តើមប្រមូលព័ត៌មាន យើងត្រូវពិនិត្យមើលព័ត៌មានដែលមានស្រាប់ ។ ព័ត៌មានដែលមានស្រាប់នេះ គឺជាព័ត៌មានដែលត្រូវបានប្រមូលដោយអ្នកដទៃ ។ ដូច្នេះជាការសំខាន់ យើងត្រូវមានប្រព័ន្ធរក្សាព័ត៌មាន និងឯកសារមួយដ៏ល្អ ។ ដូច្នេះ ការប្រមូលព័ត៌មានរបស់យើងកន្លងមកអាចជួយយើងនាពេលអនាគត ។

ប្រភពទិន្នន័យមួយ ដែលមានទិន្នន័យសម្រាប់គ្រប់ឃុំ សង្កាត់ទាំងអស់ហើយដែលត្រូវបានធ្វើបច្ចុប្បន្នភាព ជារៀងរាល់ឆ្នាំ គឺ ប្រព័ន្ធទិន្នន័យឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចរកបានព័ត៌មានមួយចំនួនសម្រាប់ភូមិ នីមួយៗ ចេញពីប្រព័ន្ធទិន្នន័យឃុំ សង្កាត់នេះផងដែរ ។

បើសិនជាព័ត៌មានដែលយើងត្រូវការ តែមិនទាន់មាននៅឡើយ ដូចនេះយើងត្រូវពិចារណាថា តើត្រូវប្រមូលព័ត៌មានទាំងនោះយ៉ាងដូចម្តេច ។ ព័ត៌មាននេះហៅថា **<u>ព័ត៌មានថ្មី ដែលត្រូវប្រមូល</u>** ។ ព័ត៌មានបែបនេះ គឺជាព័ត៌មានដែលយើងត្រូវចុះប្រមូលជាពិសេសសម្រាប់គោលបំណងរបស់យើង។ ជាការសំខាន់ យើងត្រូវប្រុងប្រយ័ត្នឱ្យបានខ្ពស់ថា តើត្រូវប្រមូលព័ត៌មានអ្វីខ្លះសម្រាប់គោលបំណងរបស់យើងដោយជៀសវាងការប្រមូលព័ត៌មានដែលមិនសូវចាំបាច់ ។

ពេលប្រមូលព័ត៌មានស្តីពីការអនុវត្តគម្រោង មានទិដ្ឋភាព ២ យ៉ាងត្រូវយកចិត្តទុកដាក់ជាពិសេសគឺ៖

- **ផលប៉ះពាល់ទៅលើស្ត្រី៖** ជារឿយៗគម្រោងមួយ មិនបានផ្តល់ផលប្រយោជន៍ដល់បុរស និងស្ត្រីស្មើគ្នានោះទេ ។ ជួនកាលបុរសបានទទួលផលប្រយោជន៍ពីគម្រោងច្រើនជាងស្ត្រី ហើយលើស ពីនេះទៀត ស្ត្រី មានស្ថានភាពកាន់តែអាក្រក់ជាងមុន ។ ដូច្នេះជាការសំខាន់មិនគ្រាន់តែប្រមូលព័ត៌មានអំពី ប្រជាពលរដ្ឋដែលទទួលផលប្រយោជន៍" ប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រមូលពត៌មានអំពី "ស្ត្រី ដែលទទួលផលប្រយោជន៍" និង "បុរសដែលទទួលផលប្រយោជន៍" ដោយឡែកពីគ្នា។

- **ផលប៉ះពាល់ទៅលើអ្នកក្រីក្រ ឬជនងាយរងគ្រោះ ៖** ប្រសិនបើយើងមិនបានប្រុងប្រយ័ត្នទេ គម្រោងមួយ អាចបម្រើផលប្រយោជន៍ឱ្យតែប្រជាពលរដ្ឋដែលមានជីវភាពធូរធារ នៅក្នុងឃុំ សង្កាត់ប៉ុណ្ណោះ

ដោយមិន បានផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលក្រីក្រ ឬជនងាយទទួលរងគ្រោះនោះទេ។ យើងត្រូវធ្វើការ សង្កេតថា តើប្រជាពលរដ្ឋក្រីក្រ ឬជនងាយទទួលរងគ្រោះបានទទួល ឬមិនបានទទួលផលប្រយោជន៍ ហើយប្រសិនបើពួកគេបានទទួលផលប្រយោជន៍ តើទំហំនៃផលប្រយោជន៍ដែលពួកគេបានទទួលមានទំហំ ប៉ុន្មាន ប្រៀបធៀបជាមួយប្រជាពលរដ្ឋដទៃទៀត ដែលទទួលផលប្រយោជន៍ពីគម្រោងដូចគ្នានោះ?

### ៣.២.២ ឧបករណ៍សម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីជាជំនួយក្នុងការប្រមូលព័ត៌មាន យើងមានវិធីសាស្ត្រ និងឧបករណ៍ជាច្រើនដែលយើងអាចប្រើបាន។ ឃុំ សង្កាត់នីមួយៗអាចបង្កើតឧបករណ៍ផ្សេងៗ សម្រប់គោលបំណងនេះ អាស្រ័យទៅតាមការចាំបាច់ និងភាពងាយស្រួលរបស់ខ្លួន។ សៀវភៅមេរៀននេះ នឹងបង្ហាញដោយសង្ខេបនូវឧបករណ៍ចំនួន៦ ដូចខាងក្រោមៈ

- តារាងតាមដាន ត្រួតពិនិត្យគម្រោងអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់
- ទម្រង់តាមដាន ត្រួតពិនិត្យការអនុវត្តគម្រោង
- ទម្រង់វាយតម្លៃគម្រោង
- សៀវភៅកំណត់ហេតុ
- បញ្ជីត្រួតពិនិត្យ និង
- កាលវិភាគតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

## ៣.៣ ការវិភាគព័ត៌មាន

បន្ទាប់ពីព័ត៌មានត្រូវបានប្រមូលរួចហើយ ប្រការសំខាន់ ត្រូវពិនិត្យព័ត៌មានទាំងនេះឱ្យបានដិតដល់ដើម្បីបញ្ជាក់ព័ត៌មាននេះអាចប្រាប់យើងពីអ្វីខ្លះ។ តាមរយៈការវិភាគព័ត៌មាន យើងអាចធ្វើសេចក្តីសន្និដ្ឋាន និងអាចវិនិច្ឆ័យការរីកចម្រើ និងគុណភាពការងារ។ ជាការប្រសើរការវិភាគព័ត៌មាននេះ មិនគួរធ្វើឡើងដោយមនុស្ស ម្នាក់ ឬ២នាក់នោះទេ ប៉ុន្តែត្រូវធ្វើជាមួយមនុស្សជាច្រើនគ្នា (ឧទាហរណ៍ ៖ នៅក្នុងគណៈកម្មាធិការកសាង ផែនការ និងថវិកា ឬជាមួយគណៈកម្មការគ្រប់គ្រងគម្រោង)។

នៅពេលយើងវិភាគពត៌មាន យើងត្រូវពិនិត្យមើលថា តើការអនុវត្តគម្រោងមានការប្រែប្រួលអ្វីខ្លះ ដូចជាការរីកចម្រើន ឬ ការធ្លាក់ចុះដែលយើងសង្កេតឃើញ ឬការប្រែប្រួលណាមួយដែលយើងពិនិត្យឃើញ ក្នុងកំឡុងពេលណាមួយ ឬទីកន្លែងណាមួយ)។ ការវិភាគពត៌មាន ក៏ត្រូវពិនិត្យផងដែរទៅលើភាពដូចគ្នា ឬភាពខុសគ្នា ពីអ្វីដែលយើងបានសង្ឃឹមទុកជាមុន ។

តើយើងមានពិនិត្យឃើញការប្រែប្រួលអ្វីដែរឬទេ រវាងភូមិនីមួយៗក្នុងឃុំ សង្កាត់? តើអ្វីដែលយើងសង្កេតឃើញ ថាដូចគ្នាទៅនឹងអ្វីដែលអ្នកឆ្លើយតបនឹងការសម្ភាសន៍របស់យើងឬទេ? តើការរីកចម្រើននៃការអនុវត្តគម្រោងដែលអ្នកទទួល ការបានរាយការណ៍ឱ្យយើង ដូចគ្នាទៅនឹងអ្វីដែលយើងបានចុះទៅពិនិត្យគម្រោង ផ្ទាល់ដែរឬទេ? តើពត៌មានដែលយើងបានប្រមូលគ្រប់គ្រាន់ដែរឬទេ? តើយើងអាចពិនិត្យឃើញតំរុយអ្វីខ្លះដែរ ឬទេពីព័ត៌មានដែលយើងបានប្រមូល? (ដូចជាការអនុវត្តគម្រោងផ្តោតទៅតែមួយភូមិ ឬ៩០ភាគរយនៃគម្រោងមួយ ត្រូវបានអនុវត្តយឺត និងខ្ជីខ្ជារដោយអ្នកទទួលការ។

ប្រសិនបើ ប្រភពព័ត៌មាន និងវិធីសាស្ត្រនៃការវិភាគព័ត៌មានផ្សេងៗគ្នា តែផ្តល់ឱ្យយើងនូវការសន្និដ្ឋានប្រហាក់ប្រហែលគ្នា នោះយើងប្រហែលជាអាចជឿលើការរកឃើញ និងការសន្និដ្ឋានរបស់យើង។ ប៉ុន្តែបើមានភាពផ្ទុយគ្នា ជាមួយនឹងលទ្ធផលនៃការវិភាគរបស់យើង យើងត្រូវព្យាយាមស្វែងយល់ថា តើមូលហេតុអ្វីបានជាវាខុសគ្នា។ ករណីនេះ យើងត្រូវប្រមូល និងវិភាគព័ត៌មានមួយចំនួនបន្ថែមទៀត។

## ៣.៤ ការប្រើប្រាស់សេចក្តីសន្និដ្ឋាន

ដំណាក់កាលចុងក្រោយនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គឺការប្រើប្រាស់សេចក្តីសន្និដ្ឋាននៃការវិភាគព័ត៌មាន ។ សេចក្តីសន្និដ្ឋាន ត្រូវបានប្រើប្រាស់ដើម្បី៖

- ធានានូវគណនេយ្យភាព (ការទទួលខុសត្រូវខ្ពស់)
- កែលំអការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចចិត្ត
- ជំរុញ ឬលើកទឹកចិត្តឱ្យមានការរៀនសូត្រ និង
- ធានាគុណភាព និរន្តភាព និងប្រសិទ្ធភាពនៃគម្រោង

❖ **គណនេយ្យភាព មាន២គឺ៖**

- ទី១ គណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំពោះប្រជាពលរដ្ឋដែលបានបោះឆ្នោតជ្រើសរើសពួកគេ។ ព័ត៌មានដែលទទួលបានពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ និង ចែកជូនដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ ។ ទន្ទឹមនឹងនេះ ឃុំ សង្កាត់ត្រូវធ្វើការ ផ្សព្វផ្សាយរបាយការណ៍ សង្ខេបមួយទំព័រ ស្តីពីការអនុវត្តគម្រោង និងការងារគ្រប់គ្រងឃុំ សង្កាត់ ជូនសាធារណៈជនរៀងរាល់ខែ ។
- ទី២ គណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំពោះអាជ្ញាធរថ្នាក់លើ ព្រោះថា ជាទូទៅអាជ្ញាធរ ថ្នាក់លើតែងតែចង់ដឹងថា តើឃុំ សង្កាត់បានអនុវត្តការងារដូចបានរំពឹងទុកដែរឬទេ?

❖ **កែលម្អការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចចិត្ត**

- ប្រសិនបើការតាមដាន ត្រួតពិនិត្យ ពុំបានបង្ហាញថា មានបញ្ហាអ្វីចំពោះការអនុវត្តគម្រោងទេនោះ ឃុំ សង្កាត់ ប្រហែលជាពុំចាំបាច់ធ្វើអ្វីទេ លើកលែងតែចង់ធ្វើការផ្លាស់ប្តូរ ដើម្បីឱ្យទទួលលទ្ធផលកាន់តែ ប្រសើរឡើងថែមទៀតប៉ុណ្ណោះ ។ ប្រសិនបើការតាម ដានត្រួតពិនិត្យបានបង្ហាញថាមានបញ្ហានោះ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិនិត្យមើលថាតើបញ្ហាទាំងនេះ នឹងអាចធ្វើឱ្យមានផលប៉ះពាល់អ្វីខ្លះ ហើយត្រូវពិនិត្យមើលថា តើត្រូវធ្វើអ្វីខ្លះបាន ដើម្បីដោះស្រាយបញ្ហាទាំងនោះ ឬដើម្បីធ្វើឱ្យបញ្ហា ទាំងនោះប្រសើរជាងមុន ។
- ប្រសិនបើឃុំ សង្កាត់ អាចដោះស្រាយបញ្ហាដោយខ្លួនឯង ពួកគេត្រូវចាត់វិធានការភ្លាមៗ។ កិច្ចការ នេះអាចមានការពាក់ព័ន្ធទៅនឹងការកែសម្រួលនូវរបៀបអនុវត្តសកម្មភាព ទីកន្លែង និងពេលវេលា ឬ កែប្រែទំហំសកម្មភាព។ ប្រសិនបើឃុំ សង្កាត់ ពុំអាចដោះស្រាយដោយខ្លួនឯងបានទេ ឃុំ សង្កាត់ ត្រូវជូនដំណឹងដល់ខេត្ត ក្រុង អំពីបញ្ហាទាំងនោះ ហើយបើសិនជាមានលទ្ធភាព សូមបញ្ជាក់ផងដែរអំពី មធ្យោបាយដែលអាចដោះស្រាយបញ្ហាទាំងនោះបាន។

❖ **ជំរុញ ឬលើកទឹកចិត្តអោយមានការរៀនសូត្រ**

អ្វីដែលទទួលបានពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ជាព័ត៌មានដែលមានសារៈប្រយោជន៍ នៅពេលធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ឆ្នាំក្រោយ។ ប្រសិនបើមានកិច្ចការអ្វីដែលអនុវត្តទៅមិនបានល្អ នៅក្នុងឆ្នាំនេះ ឃុំ សង្កាត់ គួរតែធ្វើការកែសម្រួលវិធីសាស្ត្រអនុវត្តនៅឆ្នាំបន្ទាប់។

❖ **ធានាគុណភាព និរន្តភាព និងប្រសិទ្ធភាពនៃគម្រោង**

បើសិនជាឃុំ សង្កាត់ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកាន់តែសកម្ម អ្នកអនុវត្តគម្រោង ឬសកម្មភាពប្រាកដជាខិតខំអនុវត្តការងារបានយ៉ាងត្រឹមត្រូវជាមិនខាន ដើម្បីធានាឱ្យបានគុណភាពល្អ។ លទ្ធផលដែលល្អ និងមានគុណភាព គឺអាចធានាឱ្យមានការប្រើប្រាស់យូរអង្វែងព្រមទាំងចំណាយ ត្រិបត្តិការ និងចំណាយថែទាំតិច។ ក្នុងន័យនេះ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ឃុំ សង្កាត់លើគេម្រងាអភិវឌ្ឍន៍នានា ដែលបាននឹងកំពុងអនុវត្តនៅក្នុងឃុំ សង្កាត់របស់ខ្លួននឹងអាចធ្វើឱ្យ ការអនុវត្តគេម្រងាមានប្រសិទ្ធភាព និងធានាបាននូវនីរន្តភាព។

## ពន្យល់ពាក្យគន្លឹះ

| ពាក្យគន្លឹះ | ពន្យល់អត្ថន័យ | ទំព័រ |
|---|---|---|
| **ការចិញ្ចឹមជីវិត** | រួមបញ្ចូលសមត្ថភាព ទ្រព្យសម្បត្តិ (រួមទាំងធនធានសង្គម និងសម្ភារ និង សកម្មភាពចាំបាច់) សម្រាប់ជាមធ្យោបាយទ្រទ្រង់ការរស់នៅ និងជីវភាព ប្រចាំថ្ងៃ ។ *(ការអភិវឌ្ឍនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា ២០០៥)* | ១៥ |
| **ក្រុមប្រឹក្សាឃុំសង្កាត់** | ជាសមត្ថកិច្ចរដ្ឋបាលមូលដ្ឋាននៅថ្នាក់ទាបបំផុតដែលកើតឡើងពីការបោះឆ្នោត និងដែលមានអំណាចក្នុងការកសាងផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព ។ (និន្នាការ បញ្ហាប្រឈម និងគំនិតច្នៃប្រឌិតថ្មីៗ២០០៩ ) | ៨ |
| **គម្រោង** | ជាបណ្តុំនៃសកម្មភាពដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកហើយ សកម្មភាពទាំងនោះកើតចេញពីគោលបំណង និងគោលដៅដែលគម្រោង បានកំណត់ឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមអ្នកទទួលផលណាមួយ។*(សៀវភៅមេរៀនស្តីពីការគ្រប់គ្រងគម្រោងនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល)២០១០* | ៣ |
| **គោលការណ៍** | ច្បាប់, មាត្រា, មាតិកា, ភស្តុតាង, គោលពាក្យ គោលសេចក្តី | ៨ |
| **គណនេយ្យភាព** | នេះ (នៅគ្រប់វិស័យគ្រប់ផ្នែកទាំងអស់) | |
| **គ្រប់គ្រង** | ជាដំណើរការនៃការធ្វើផែនការ ការសម្របសម្រួល ការជំរុញលើកទឹកចិត្ត ការដឹកនាំ ឬតម្រង់ទិសព្រមទាំងមានការត្រួតពិនិត្យដោយប្រើប្រាស់ធនធាន មនុស្ស និងធនធានសំខាន់ៗផ្សេងៗទៀតដើម្បីសម្រេចគោលដៅគម្រោង ឬស្ថាប័នមួយ។ *(សៀវភៅមេរៀនស្តីពី ការគ្រប់គ្រងគម្រោង ២០១០នៃវិទ្យាស្ថានសិក្សា*<br>*ស្រាវជ្រាវ និងបណ្តុះបណ្តាល)* | ៣ |
| **ឆន្ទៈ** | ការលះបង់ធ្វើអ្វីមួយ | ១២ |
| **តម្លាភាព** | មានន័យថាការសម្រេចចិត្ត និងការអនុវត្តត្រឹមត្រូវតាមបទដ្ឋានច្បាប់ ព័ត៌មានបើកចំហ និងងាយទទួលបានផ្ទាល់លើសារព័ត៌មានដល់អ្នកដែលរងផលប៉ះពាល់ដោយការសម្រេចចិត្តនោះ។ មានព័ត៌មានគ្រប់គ្រាន់ ហើយងាយយល់ គ្មានការលាក់លៀម។ *(និន្នាការ បញ្ហាប្រឈម និងគំនិតច្នៃប្រឌិតថ្មីៗ ២០០៩ )* | ៥ |
| **ទស្សនៈ** | គំនិត ឬមតិយោបល់ ឬការឃើញ ដំណើរយល់ឃើញ ។<br>*(វចនានុក្រមខ្មែរ២០០៧ )* | ១ |
| **ទស្សនវិស័យ** | ទស្សនៈ ឬគំនិតដែលសម្លឹងមើលទៅឆ្ងាយ ឬការគិតថាអ្វីនឹងកើតឡើងនៅពេលអនាគត។ | ២៤ |

| | | |
|---|---|---|
| **បរិបទ** | បែបផែន, គំរូ, ស្ថានភាព ឧ.បរិបទនៅភ្នំពេញប្រជាជនមានភាពស៊ីវិល័យជាងជនបទ | ៥ |
| **ប្រជាធិបតេយ្យ** | ការដឹកនាំដោយមានចូលរួម (មតិភាគច្រើន) ឬភាពនៃប្រទេសដែលមានប្រជារាស្ត្រអធិបតី គឺប្រទេស ឬរដ្ឋបាលដែលមានប្រជាជនជាធំក្នុងការរើសតំណាងរបស់ខ្លួនឱ្យជាអ្នកសម្រេចកិច្ចការក្នុងប្រទេស....។ *(វចនានុក្រមខ្មែរ ២០០៧ )* | ១ |
| **និរន្តរភាព** | ភាពយូរអង្វែងមិនចេះសាបសូន្យ ឬភាពឥតចន្លោះ ឧទាហរណ៍ៈ សូមលោកបានប្រកបដោយសេចក្តីសុខជានិរន្តរទៅ ។ (វចនានុក្រមខ្មែរ ២០០៧ ) | ១ |
| **និតីវិធិ** | របៀបចាត់ការដែលច្បាប់បានកំណត់របៀបដែលតុលាការប្រើប្រាស់ដើម្បីចាត់ចែងរឿងក្តីតាំងពីដើមរហូតដល់ចប់វិធាន និងវិធីសាស្ត្រលើកិច្ច ដំណើរការនៃបណ្តឹងមួយដោយ គិតទាំងការជជែកដេញដោលការបង្ហាញភស្តុតាងនិងសិទ្ធិរបស់អ្នកចូលរួមវិធានការណ៍តាមច្បាប់ ។ *(វចនានុក្រមខ្មែរ ២០០៧)* | ២៩ |
| **យុទ្ធសាស្ត្រ** | ក្បួន ឬវិធីសម្រាប់យកទៅអនុវត្តដែលជាការប៉ិនប្រសប់ក្នុងការរៀបចំផែនការដោយប្រុងប្រយ័ត្ន ដើម្បីសំរេចគោលដៅអ្វីមួយ។ ការគិតគូរ និងរៀបចំផែនការជាយុទ្ធសាស្ត្រដែលអនុវត្តបានល្អណាស់ក្នុងពេលសង្គ្រាមគឺត្រូវយកមកប្រើផងដែរក្នុងការកសាងសន្តិភាពនិងគ្រប់គ្រងទំនាស់ឱ្យបានជោគជ័យ។ ឧ.ផែនការយុទ្ធសាស្ត្រ *(វចនានុក្រមខ្មែរ ២០០៧)* | ៣ |
| **លក្ខណៈវិនិច្ឆ័យ** | បែបបទ ឬក៏ជាគោលការណ៍ ដែលគេប្រើប្រាស់ ដើម្បីធ្វើការវិនិច្ឆ័យ ធ្វើការវាយតម្លៃ ឬធ្វើសេចក្តីសម្រេចចិត្ត ។ *(វចនានុក្រមខ្មែរ ២០០៧)* | ៨ |
| **វិសាលភាព** | ភាពទូលំទូលាយ ឬភាពដែលលាតសន្ធឹងទៅ (ឧទាហរណ៍ប្រៈទេសកម្ពុជាយើងពីដើមមានវិសាលភាពធំទូលាយណាស់) ។ *(វចនានុក្រមខ្មែរ ២០០៧)* | ១៨ |
| **វិធីសាស្ត្រ** | កម្រងវិធីនានាសម្រាប់ការសិក្សាបច្ចេកទេស ឬវិទ្យាសាស្ត្រណាមួយ។ បែបផែនមានរបៀបរៀបរយសម្រាប់ដឹកនាំកិច្ចការអ្វីមួយ។ *(វចនានុក្រមខ្មែរ ២០០៧)* | ៥ |
| **សហគមន៍** | សំដៅលើក្រុមមនុស្សនៅក្នុងភូមិមួយ ឬច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានចំណាប់អារម្មណ៍រួមគ្នាលើសង្គម បរិស្ថាន វប្បធម៌ ប្រពៃណី និងសេដ្ឋកិច្ច ព្រមទាំងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់មួយ (ដែលពួកគេរស់នៅក្នុង ឬក្បែរ) ប្រកបដោយនិរន្តរភាព ដើម្បីចិញ្ចឹមជីវិត និងលើកស្ទួយកម្រិតជីវភាព ។ *(និន្នាការ បញ្ហាប្រឈម និងគំនិតច្នៃប្រឌិតថ្មីៗ២០០៩ )* | ៥ |
| **សហគមន៍ព្រៃឈើ** | ជាពាក្យដែលមានន័យទូលំទូលាយដោយរួមបញ្ចូលប្រព័ន្ធនានានៃការគ្រប់គ្រងព្រៃឈើ និងរួមបញ្ចូលរាល់សកម្មភាព ដើម្បីអនុវត្តន៏របស់សហគមន៏ព្រៃឈើជាក់លាក់ក្នុងការគ្រប់គ្រង អភិវឌ្ឍន៏ ការពារ ប្រើប្រាស់ និងផលប្រយោជន៏បានមកពីធនធានព្រៃឈើ ជាពិសេសនៅក្នុងតំបន់ដែលបានកំណត់ជាមុន ។ | ៤ |

| | | |
|---|---|---|
| | *(និន្នាការ បញ្ហាប្រឈម និងគំនិតច្នៃប្រឌិតថ្មីៗ ២០០៩ )* | |
| **សិទ្ធិអំណាច** | ប្រើប្រាស់សិទ្ធិរបស់ក្នុងការធ្វើអ្វីមួយ | ៩ |
| **សិក្សាស្រាវជ្រាវ** | ការរៀនសូត្រដើម្បីស្វែងរកអ្វីដែលថ្មីៗនៅក្នុងតំបន់ណាមួយ | ១២ |
| **សូចនាករ** | ចំណុចសម្រាប់វាស់វែង | ៣២ |
| **សមធម៌** | ភាពយោគយល់គ្នារវាងបុរស និងស្ត្រី | ៤ |
| **សមភាព** | ភាពស្មើគ្នារវាងបុរស និងស្ត្រី | ៦ |
| **ស្នូល** | ចំណុចសំខាន់ | ២២ |
| **ហានិភ័យ** | ការប្រថុយប្រថានក្នុងអនុវត្ត | ៩ |
| **អត្តសញ្ញាណ** | កំណត់អ្វីមួយ ឬកត់សម្គាល់ ឬគ្រឿងសម្គាល់ខ្លួន សញ្ញាដែលអាចសម្គាល់បានថាព័ត៌មាននោះៗពិតជាមាន ឬត្រូវចម្លើយរូបបុគ្គល ឬវត្ថុណាមួយដូចជាមនុស្ស និងសត្វតែងមានអត្តសញ្ញាណផ្ទាល់ខ្លួនជាដរាប។ *(វចនានុក្រមខ្មែរ ២០០៧)* | ២២ |
| **អព្យាក្រិត** | មិនមានភាពលម្អៀង (ចំណុចកណ្តាល) ឬដែលមិនច្បាស់ពុំប្រាកដមិនដាច់ស្រេចមិនស្រេចជាទៅខាងណា ដែលនៅជាកណ្តាល ហើយមិនប្រកាន់បក្សពួកមិនចូលជាបក្សពួកខាងណា ។ ឧទាហរណ៍ៈ ប្រទេសអព្យាក្រឹត ជាប្រទេសដែលមានភាពជាកណ្តាល ហើយមិនលម្អៀង។ *(វចនានុក្រមខ្មែរ ២០០៧ )* | ៩ |
| **អភិបាលកិច្ច** | ជាទូទៅសំដៅលើស្ថាបន័នៃសង្គមមនុស្ស ដែលធ្វើការរួមគ្នាដើម្បី គ្រប់គ្រងកិច្ចការសាធារណៈ ។ អភិបាលកិច្ចពាក់ពន្ធ័ដំណើរការមួយ (ឬច្រើន) ដែលតាមរយៈដំណើរការនោះ អង្គភាពដឹកនាំត្រូវបានជ្រើសរើសដាក់ឱ្យទទួលខុសត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងត្រូវផ្លាស់ប្តូរ និងទទួលការជ្រើសរើស ។ សមត្ថភាពរបស់ស្ថាបន័ដឹកនាំនៅក្នុងការគ្រប់គ្រងធនធានមានប្រសិទ្ធភាពមានជាអាទិ៍ការបង្កើត និងអនិវត្តគោលនយោបាយ (គោលបំណង) និង បទបញ្ញា (លក្ខន្តិកៈ) ពង្រឹងការអនុវត្តច្បាប នឹងរក្សាសណ្តាប់ធ្នាប់ ព្រមទាំងការបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ធានាស្ថេរភាពសង្គម និង សេដ្ឋកិច្ច និងការផ្តល់សុពលភាពជាប្រចាំសម្រាប់ស្ថាបន័នានា នៅក្នុងក្របខ័ណ្ឌនៃសង្គមកិច្ច។ *(ការអភិវឌ្ឍនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅប្រទេសកម្ពុជា ២០០៥ )* | ៤ |
| **ឧបករណ៍** | សម្ភារសម្រាប់អនុវត្តសកម្មភាព (ឧ. ឯកសារ បញ្ជីសំណួរ......) | ១០ |
| **ឥទ្ធិពល** | ប្រសិទ្ធភាពរបស់គម្រោងបែបវិជ្ជមាន ឬកម្លាំងនៃឬទ្ធិ កម្លាំងនៃសេចក្តីសម្រេចកម្លាំងអនុភាព ឬអំណាច ។ កំណើននៃការរេចរិលបរិស្ថាននៅក្នុងពេលវេលាណាមួយបណ្តាល មកពីសកម្មភាព ជាច្រើនបញ្ចូលគ្នានៅក្នុងតំបន់ណាមួយ ។ សកម្មភាពមួយៗដាច់ដោយ ឡែកតែឯង អាចមានឥទ្ធិពលតែតិចតួច (ដូចជាផ្សែងចេញពីរថយន្តមួយ ឬពីរោងចក្រមួយ) ។ | ៤ |

| | | |
|---|---|---|
| | (វចនានុក្រមខ្មែរ ២០០៧ ) | |

## ឯកសារយោង

សៀវភៅណែនាំស្តីពី *ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ ឃុំ/សង្កាត់ លើការងារអភិវឌ្ឍន៍មូលដ្ឋាន* គណៈកម្មាធិការជាតិគាំទ្រ ឃុំ/សង្កាត់ ២០០៤

សេចក្តីណែនាំ ស្តីពី *ការកសាងផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ និងកម្មវិធីវិនិយោគឃុំ/សង្កាត់* គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ខែកក្កដា ២០០៧

**អឿ សុធារ័ត្ន និង ចូវ សោភ័ណ** (២០០៧)ការណែនាំអំពីការវាយតម្លៃជនបទដោយមានការចូលរួមដើម្បីគ្រប់ គ្រង និងអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ។ ក្រសួងធនធានទឹក និងឧតុនិយម វិទ្យាស្ថានគ្រប់គ្រងទឹកអន្តរជាតិ និង កិច្ចសហប្រតិបត្តការបច្ចេកទេសបែលហ្ស៊ិក។

A.S.C. Davis (2001). *Participatory Rural Appraisal*. Rural Travel and Transport Program. Retrieved on Jul 20, 2010
http://www.transport-links.org/rtkb/english/Module%205%5C5_6a%20Participatory%20 Rural%20Appraisal.pdf-

Anantha Kumar Duraiappah, Pumulo Roddy and Jo-Ellen Parry (June 2005). *Have Participatory Approaches Increased Capabilities?* iisd. Retrieved on Jul 20, 2010
http://www.iisd.org

Center for International Forest Research (CIFOR) (2007). *Participatory Planning: What is participatory planning?* Retrieved on 20 Aug, 2010
http://www.cifor.cgiar.org/sourcebook/part_two_tools/pp_what_is_pp.html

CIVICUS, 2009; Stephen P. Robbins and Mary Coultar, 1996

Economic and Social Development Department. *Module II: Introducing Participatory Approaches, Methods and tools*. FOA Organization. Retrieved on Jul 20, 2010.
http://www.foa.org/docrep/006/ad424e/ad424e03.htm

http://creatingminds.org/tools/kipling.htm;
http://www.davebaldwinconsulting.com/5W1H.html

Mr. Kim Sarin and Mr. Sy Ramuny (Dec 2005). *Collective Experiences of Action Research and Facilitation on Community Forestry and Community Protected Area*. IDRC and CRDI.

Mr. Kim Nong, PMMR Chief. *Participatory Methods in Community-based Costal Resource Management*. IDRC, CIDA, and HRR.
Investor Words website. *Planning*. Retrieved on 20 Aug 2010.
http://www.investorwords.com/3710/planning.html

Prof. Seak Sophat (June 2010). *Participatory Land Use Planning with Special Reference to Watershed Management*. Department of Environmental Science at Royal University of Phnom Penh.

Social-Economic Planning process (2007). *Participatory Rural Appraisal Manual*. Quang Ngai Province. Retrieved on Jul 20, 2010
http://www.rudep.org/Doc/ADD0609_3_PRA%20Guide%20for%20Facilitators_2006.pdf

Time Management Guide website (2002). *What is planning and why you need to plan*. Retrieved on 20 Aug, 2010
http://www.time-management-guide.com/planning.html








## វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល

ផ្លូវលេខ៣០ ផ្ទះលេខ៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន

ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ ២៥០៩

ទូរស័ព្ទ ៨៥៥ (0) ២៣ ៩៩៤ ៩៣៥

ទូរសារ ៨៥៥ (0) ២៣ ២២៤ ១៧១

អ៊ីម៉ែល៖ info@learninginstitute.org

គេហទំព័រ៖ www.learninginstitute.org



២០១២ រក្សាសិទ្ធិគ្រប់យ៉ាង



*"សៀវភៅបណ្តុះបណ្តាលនេះត្រូវបានផលិតក្រោមជំនួយសហភាពអឺរ៉ុប។ ខ្លឹមសារដែលបានបង្ហាញក្នុងសៀវភៅនេះជាការទទួលខុសត្រូវរបស់វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។"*